# ដោយក្តីជំនឿ លោកម៉ូសេ

សូមអរគុណ បងប្រុសនេវីល។ អរុណសួស្តី អ្នកទាំងអស់គ្នា។ វាជាការប្រសើរណាស់ដែលបានមកទីនេះ មកក្នុងរោងឧបោសថថ្ងៃនេះ។ ហើយខ្ញុំបាន គិតថា ប្រហែលជាបងប្រុសនេវីល នឹងអធិប្បាយនៅព្រឹកនេះ តែខ្ញុំនឹងព្យាយាម នៅយប់នេះ។ ខ្ញុំបានត្រឡប់មកមើលមេរៀនថ្នាក់ថ្ងៃអាទិត្យ នៅព្រឹកមិញ។ ហើយអ្វីដែល...បើព្រះសព្វព្រះហឫទ័យ យើងនឹងព្យាយាម—ដើម្បីរៀនមេរៀន ថ្នាក់ថ្ងៃអាទិត្យនេះ។

2 ឥឡូវនេះ វាមានរយៈពេលពីរសប្តាហ៍ទៅហើយ ចាប់តាំងពី ខ្ញុំបានចូលមក។ ហើយក៏ភ័យណាស់ដែរដូចអ្នកដឹងស្រាប់ហើយ នៅលើវាលដ៏ធំ ខ្ញុំពិតជាហត់ណាស់ ហើយស្ទើរតែមិនអាចទៅមុខទៀតបាន។ ដូច្នេះហើយខ្ញុំត្រូវតែចូលមកក្នុង ដើម្បីសម្រាកបន្តិច។ ហើយខ្ញុំត្រូវចំណាយពេលប្រមាណបីថ្ងៃឡើងទៅ វូលក្រីក(Wolf Creek) ទំនប់វារីអគ្គីសនីនៅរដ្ឋគេនតាគី(Kentucky)ជាស្រុកកំណើតខ្ញុំ។ ខ្ញុំគិតថា "អូខ្ញុំមានអារម្មណ៍ថាអស្ចារ្យណាស់ឥឡូវនេះ។ ខ្ញុំសុខសប្បាយទេ។"

3 ហើយពេលខ្ញុំទៅដល់ផ្ទះវិញ រឿងដំបូងដែលខ្ញុំជួបមុនគេគឺជាកិច្ចការមួយចំនួន របស់រដ្ឋាភិបាលស្តីអំពីពន្ធលើប្រាក់ចំណូល។ ខ្ញុំត្រូវធ្វើដំណើរ ត្រឡប់ក្រោយម្តងទៀត។ ដូច្នេះខ្ញុំដឹងថាវានឹងចំណាយពេលច្រើនជាងមួយ សប្តាហ៍ឬពីរ ដើម្បីខ្ញុំ សម្រាក។

4 ហើយបេសសកកម្មរបស់ខ្ញុំត្រូវបានផ្លាស់ប្តូរឥឡូវនេះ។ ហើយខ្ញុំគ្មានកាលវិភាគ កិច្ចប្រជុំណាទេ។ នោះជាហេតុផលដែលខ្ញុំញែកខ្លួនដោយឡែក ហើយគិតថា ឥឡូវនេះសម្រាប់ប៉ុន្មានសប្តាហ៍ក្រោយ ខ្ញុំនឹងគ្រាន់តែសម្រាកឲ្យពេញលេញ ហើយរង់ចាំព្រះអម្ចាស់។

5 ហើយអ្នកទាំងអស់គ្នាជាច្រើននៅក្នុងទីនេះ ដែលជាអ្នកដែលមានវ័យចំណាស់ ដែលបាននៅជាមួយយើងជាយូរមកហើយ ត្រូវចងចាំថា អ្វីដែលព្រះអម្ចាស់បាន មានបន្ទូលប្រាប់យើង ទ្រង់តែងតែសម្រេចតាមបន្ទូលទ្រង់។

6 សូមចាំថា នៅពេលព្រះវិហារនៅទីនេះចាប់ផ្តើមដំបូង នៅព្រឹកដែលយើងបានដាក់ថ្មនៃព្រះពន្លា របៀបដែលទ្រង់...វាត្រូវបានសរសេររួចហើយ ក៏បានផ្តេកថ្មនោះ នៅលើសន្លឹកនៃព្រះគម្ពីររបស់ខ្ញុំ។ នៅព្រឹកនោះ ការបើកសម្តែងដ៏អស្ចារ្យបានប្រាប់ថា "នេះមិនមែនជារោងឧបោសថរបស់អ្នកទេ។"

7 ខ្ញុំបាននិយាយថា "តើទ្រង់គង់នៅឯណា ព្រះអង្គអើយ?" ហើយទ្រង់បានដាក់ខ្ញុំ នៅក្រោមមេឃ។ ហើយសម្លេងមួយបានមក។ ហើយខ្ញុំក្រឡេកមើលទៅឃើញ មានឈើឆ្កាងបីដូចជាដើមឈើនិងផ្លែរបស់វា។ អ្នកដឹងពីការបើកសម្តែងនេះជាអ្វី។ វាបានបានសរសេរចេញអស់រយៈពេលជាច្រើនឆ្នាំរួចហើយ។

8 រើសយក សៀវភៅចាស់មួយក្បាលនៅទីនោះថ្ងៃបន្ទាប់ ហើយអាននូវចំណុចខ្លះដែលព្រះបានមានបន្ទូល បានទាយទុក វាបានសំរេចរួចហើយ។ អំពីវត្ថុអនីតិជននិងអំពីសង្គ្រាមដែលនឹងកើតឡើង ព្រមទាំងអ្វីផ្សេងទៀត ដែលនឹង ត្រូវមក។

9 នៅរឿងតែពីរទេដែលនៅសល់ មួយក្នុងចំណោមទំនាយដ៏អស្ចារ្យនោះគឺ។ នោះគឺ រថយន្តបើកបរលើផ្លូវដោយបញ្ជាពីចម្ងាយ មើលទៅដូចជាស៊ុតអញ្ចឹង តែអ្នកចាំបាច់មិនបើកវាទេ។ វាគ្រប់គ្រងខ្លួនឯង។ ហើយបន្ទាប់មកវានឹងមានស្ត្រីដ៏អស្ចារ្យ ក្រោកឡើងដោយសារតែអាមេរិចគឺជាប្រទេសរបស់ស្ត្រី។ ហើយវានឹង... ស្ត្រីដ៏អស្ចារ្យនឹងក្រោកឡើង ហើយក្លាយជាប្រធានាធិបតីឬអ្វីមួយស្រដៀងហ្នឹង។ ហើយបន្ទាប់មកនឹងមានការបំផ្លាញទាំងស្រុង។ ជាតិទាំងមូលនឹងត្រូវរលាយ។

10 ហើយខ្ញុំទាយថា...ឥឡូវនេះមិនមែនជាព្រះបន្ទូលរបស់ព្រះទេ។ (ម្យ៉ាងទៀត អំពីស្ត្រី វាគឺជាព្រះអម្ចាស់។) ប៉ុន្តែខ្ញុំទាយថានៅក្នុងឆ្នាំ 1933 នោះពិភពលោកនឹងជួបការបំផ្លាញមុនឆ្នាំ 77។

11 ដូច្នេះ ខ្ញុំមិនបានដឹងថានឹងមានការបំផ្លាញអ្វីមួយដែលអាចធ្វើបានទេ វាដូចជា បានធ្វើហើយឥឡូវនេះ ប៉ុន្តែខ្ញុំបានឃើញថាប្រទេសជាតិទាំងមូលត្រូវបានបំផ្លិច បំផ្លាញ ដូចជាដើមឈើនិងអ្វីផ្សេងទៀត ដែលនៅសល់។

12 ដូច្នេះ វានៅលើផ្លូវរបស់វា។ ហើយបើសិនជាការផ្សេងទាំងអស់នេះបានសម្រេចដូចដែលទ្រង់បានមានបន្ទូលនោះក៏នឹងមានដូច្នោះដែរ។ ហើយក៏ដូចជាអ្វីដែលទ្រង បានមានបន្ទូលក្នុងបទគម្ពីរទីនេះ។ បើព្រះគ្រីស្ទ បានយាងមក

លើកទីមួយ ទ្រង់ក៏នឹងយាងមកជាលើកទីពីរដែរ។ ហើយរឿង ទាំងអស់ដែលទ្រង់មានបន្ទូល នឹងកើតឡើង។ ហើយជាការពិតយើងត្រូវដឹងថា...ចំនួនរបស់យើងគឺទើបតែត្រូវ បានហៅគឺដូចជាប្រជាជាតិមួយ ដោយដឹងថាក្រុម ជំនុំនឹងត្រូវបានលើកឡើង។ វាផ្លាស់ប្រែចិត្តនៃអ្នកគ្រប់គ្រងឬប្រព័ន្ធណាមួយ ដើម្បីដឹងថា យើងកំពុងស្ថិតក្នុង សម័យនេះឯង។ វាជាពេលវេលា ដ៏អស្ចារ្យសម្រាប់គ្រប់គ្នា ដែលរស់នៅលើផែនដី គឺឥឡូវនេះ។ នោះគឺ សម្រាប់ក្រុមជំនុំ។ ដូច្នេះខ្ញុំពិតជាចង់បានសេចក្ដី អធិស្ឋានរបស់អ្នក។

13 ហើយបន្ទាប់មកខ្ញុំបានឃើញនៅក្នុងរោងឧបោសថ ហើយខ្ញុំឃើញថាពួកគេបាន...ធ្វើការបោះឆ្នោតសារឡើងវិញនិងគ្រប់យ៉ាងនៅក្នុងព្រះវិហារ សម្រាប់អ្នកដឹកនាំជាដើម។

14 ហើយ—ហើយពួកជំនុំមានការប្រជុំតិចតួច លំបាកតិចតួច។ តែទ្រង់តែងតែប្រណីដល់ទូលបង្គំ ហើយប្រទានពរដល់ទូលបង្គំផង។ ហើយដោយសារទូលបង្គំនៅទីនេះ ហាក់ដូចជាទីបញ្ចេញពររបស់ទ្រង់។ ហើយទូលបង្គំប្រាកដថា នឹងនៅជាមួយទ្រង់ ដែលបានប្រទានពរដល់ទូលបង្គំដែរ។ ហើយព្រះអង្គតែងតែទទួលអ្វីដែលទូលបង្គំបាននិយាយ ថាជាការពិត ដូចដែលខ្ញុំបានឃើញតាមរយៈព្រះអង្គម្ចាស់។ ហើយខ្ញុំ—ខ្ញុំសរសើរព្រះ។

15 ដូច្នេះហើយ ខ្ញុំចាប់ផ្ដើមចូលមក ដើម្បីស្វែងរក ឲ្យពួកជំនុំរបស់យើងបានតំរង់ឆ្ពោះឡើង អ្នកដឹកនាំរបស់ខ្លួនសម្រាប់ការបោះឆ្នោត និងអ្វីផ្សេងទៀត។ ហើយបន្ទាប់មក—ខ្ញុំបានគិតថា ខ្ញុំនឹងចេញក្រៅដើម្បីសម្រាកបន្តិចមុនពេលដែលខ្ញុំត្រឡប់ទៅបម្រើរពន្ធកិច្ចម្ដងទៀត។

16 ចូររក្សាវានៅក្នុងចិត្ត។ ឥឡូវនេះមិនមែនសម្រាប់អ្នកនៅខាងក្រៅទេ។ គឺសម្រាប់អ្នកនៅក្នុងរោងឧបោសថនេះ។ យើងចង់ជួបប្រជុំក្នុងរោងឧបោសថនេះ ដើម្បីឲ្យអ្វីគ្រប់យ៉ាងនិងកំហុសឆ្គងទាំងអស់ រឿងទាំងអស់ដែលជាបន្ទុក ហើយប្រហែលជាអារម្មណ៍អាក់អន់ចិត្ត គ្នានិងគ្នា ទាំងអស់នោះខ្ញុំនឹងនាំវាមកម្ដងមួយៗ។ ដូច្នេះបើអ្នកមិនចង់ប្រឈមមុខនឹងវា អ្នកចាកចេញពីប្រទេសនេះ ប្រសើរជាង។ ព្រោះអ្នកមកដើម្បីប្រឈមមុខនឹងគ្រប់ការទាំងនោះ ដូចដែលយើង ធ្លាប់ជួបនៅរោងឧបោសថនេះ។ ហើយគ្រប់យ៉ាងត្រូវបានបំផ្លាញ ពីព្រោះយើង ជាបងប្អូនប្រុសស្រីដែលបានបែកបាក់ការរួបរួមគ្នា ក្នុងរូបកាយនៃព្រះគ្រីស្ទ ឆ្លង កាត់

តុរនៃព្រះពរ។ ហើយគ្មានអ្វីក្រៅពីអារក្សដែលនឹងធ្វើអ្វីគ្រប់យ៉ាង ដែលជា កំហុស ហើយនឹងបណ្តាលឲ្យមានការអន់ចិត្ត ឬស្រក់ទឹកភ្នែកឬអ្វីផ្សេងទៀត ស្រដៀង ហ្នឹង។ ហើយខ្ញុំបាននាំបងប្រុសនេវីល ហើយយើងបានចេញពីកន្លែង មួយទៅ កន្លែងមួយ ហើយនាំមនុស្សម្នាក់ៗឲ្យមកជួបជុំគ្នា រហូតដល់រោង ឧបោសថចាស់ ត្រឡប់មកវិញ បានស្អាងឡើងជាថ្មី នៅលើជើងរបស់ខ្លួន ដើម្បី ចូលទៅក្នុង អាណាចក្ររបស់ព្រះ។ ឥឡូវ ហេតុផលដែលខ្ញុំនិយាយការនេះ គឺ ដោយសារតែវា នៅក្នុងក្រុមតូចរបស់យើងផ្ទាល់នៅទីនេះ ព្រឹកនេះ។

17 ហើយឥឡូវនេះខ្ញុំនឹងសម្រាកបន្តិច រួចនឹងត្រឡប់មកវិញឲ្យឆាប់តាមដែល អាចធ្វើបាន។ ហើយខ្ញុំរំពឹងថានឹងចាកចេញទៅបម្រើបេសកកម្មម្តងទៀត។ ហើយ ម្តងនេះ បើជាព្រះហឫទ័យព្រះ នោះខ្ញុំចង់យកមូលនិធិតិចតួចដែលយើងមាន ព្រមទាំងថវិការផ្ទាល់ខ្លួនរបស់ខ្ញុំខ្លះ ចំណាយក្នុងកម្មវិធីបេសកកម្មបរទេសនេះ។ ហើយខ្ញុំចង់បានតង់ថ្មីនិងឧបករណ៍ថ្មីមួយចំនួន ហើយចាប់ផ្តើមបេសកកម្ម។ មិនមែនពីព្រះវិហារមួយទៅព្រះវិហារមួយទេ ប៉ុន្តែទៅកិច្ចប្រជុំរបស់យើងផ្ទាល់។

18 ឥឡូវ សូមកុំបោះបង់ចោលបងប្អូនដែលបានអញ្ជើញខ្ញុំ ដែលអស្ចារ្យ។ ប៉ុន្តែ អ្វីដែលសំខាន់បំផុត អ្នករកឃើញអនុសញ្ញាទាំងនេះ ពួកគេនិយាយថាអ្នកនឹង នៅទីនោះ ហើយបន្ទាប់មកមិត្តភក្តិរបស់អ្នកទាំងអស់ចូលមក ទីនោះមានស្តុធំ មួយសម្រាប់ដាក់ប្រាក់។ គ្រាន់តែបង្ហូរមនុស្សទាំងនោះចុះ។ ខ្ញុំទើបតែចាប់ផ្តើម ដឹង ឃើញទេ។ អញ្ចឹងការនោះ—នោះត្រឹមត្រូវទេ។ យើងចង់មានកន្លែង ដែល យើងអាចនាំពួកគេមក។ អ្នកមិនចាំបាច់យកលុយមកទេ។ គ្រាន់តែចូលមក ដោយខ្លួនឯង ហើយ—និងបម្រើព្រះអម្ចាស់។ ឃើញទេ? ហើយដូច្នេះឥឡូវនេះ...

19 បេសកកម្មរបស់ខ្ញុំបានផ្លាស់ប្តូរឥឡូវនេះ។ អ្នកចាំបានទេ ពេលខ្ញុំកាន់ដៃ របស់មនុស្សហើយឈរនៅទីនោះ។ ហើយព្រះបានប្រាប់ខ្ញុំពីអ្វីដែល ជាបញ្ហារបស់ ពួកគេ។ និយាយថា "វានឹងបានសម្រេច អ្នកបានដឹងពីការ សម្ងាត់នៃចិត្តរបស់ មនុស្ស។" គ្រប់គ្នាដឹងថាវាបានកើតឡើងយ៉ាងឥតខ្ចោះ ដូច ដែលបានចែង។ ឥឡូវនេះគឺជាជំហានបន្ទាប់ ដែលបានទាយឲ្យដឹងជាមុន ជាអ្វី ដែលលើសជាង ការណាមួយដែលអ្នកធ្លាប់ឃើញ។ ហើយឥឡូវនេះ នៅក្នុងការ ផ្លាស់ប្តូរ។

20 ហើយនោះក៏ជាហេតុផលដែលសាតាំងប្រឆាំងខ្ញុំ ជាមួយនឹងពន្ធលើប្រាក់ ចំណូលនោះ រដ្ឋាភិបាលព្យាយាមប្រាប់ខ្ញុំថា ខ្ញុំជំពាក់ពន្ធលើប្រាក់ចំណូល គ្រប់

កាក់ តាំងពីម្ភៃប្រាំពីរឆ្នាំមុន គឺនៅពេលទើបចូលគ្រប់គ្រងដំបូង។ វាមិនដូច្នេះ ទេ ព្រោះវាបានឆ្លងកាត់ក្រុមជំនុំនៅទីនេះ។

21 ខ្ញុំគឺជាអ្នកទទួលខុសត្រូវនៃក្រុមជំនុំនេះ។ នោះត្រឹមត្រូវណាស់។ វាកត់ត្រា នៅទីនេះ។ ដូច្នេះបើសិនជាខ្ញុំជាអ្នកទទួលខុសត្រូវ—ជាអ្នកគ្រប់គ្រងនៅព្រះវិហារ នេះ នោះគ្មានអ្វីក្នុងផែនដីនេះ...រដ្ឋាភិបាលគ្មានសិទ្ធធ្វើអ្វីទាំងអស់។ ពួកគេមិនសួរ ចម្លើយពួកជំនុំទេ។ ពួកគេកំពុងសួរខ្ញុំ ដែលជាអ្នកគ្រប់គ្រងហិរញ្ញវត្ថុនៃព្រះវិហារ។ ហើយអ្នកទទួលខុសត្រូវបានចុះហត្ថលេខាលើក្រដាសមួយនៅក្នុងធនាគារ នោះ ជាប្រាក់ទាំងអស់របស់ខ្ញុំ...ជំនួសឲ្យការសង់គ្រឹះផ្ទាល់ខ្លួន ខ្ញុំបានថ្វាយវាសម្រាប់ ព្រះវិហារនៅទីនេះព្រោះទោះជាយ៉ាងណា វាជាគ្រឹះស្វ័យប្រវត្តិមួយ។

22 ហើយដែលធ្វើដូច្នេះ គឺជួយខ្ញុំអោយគេចពីការរត់ចេញពីព្រះវិហារ បោះបង់ វា ហើយទៅនេះទៅនោះគ្មានប្រយោជន៍អីនៅទីនេះ។ បន្ទាប់ពីខ្ញុំបានសន្យាដល់ មនុស្ស ថាខ្ញុំនឹងត្រលប់មកក្រុមជំនុំវិញ នៅពេលក្រោយដើម្បីជួយពួកគេ។ នោះ ហើយជាមូលហេតុដែលខ្ញុំរក្សាវាដូច្នេះ ព្រោះខ្ញុំបានសន្យាជាមួយអ្នកជារួចហើយ។ នោះជាមូលហេតុដែលខ្ញុំស្នាក់នៅជាមួយក្រុមជំនុំជំនួសឲ្យ ការរស់នៅលក្ខណ បុគ្គល។ ហើយបើសិនអ្នកធ្វើដូច្នេះ វានឹងក្លាយជាអង្គការ។ ហើយខ្ញុំប្រឆាំង ដាច់ខាតចំពោះអង្គការ។ ដូច្នេះខ្ញុំ—ខ្ញុំនឹងរក្សាវាបែបនេះ ក្នុងព្រះហស្តរបស់ព្រះ ដូច្នេះយើងអាចបន្តសម្រាប់នគរព្រះ។

23 ឥឡូវ នៅព្រឹកនេ យើងចង់សិក្សាពីព្រះបន្ទូលដ៏មានព្រះពរនេះ។ ហើយជឿ។

24 ឥឡូវនេះខ្ញុំចង់និយាយផងដែរ...ខ្ញុំឃើញបងប្រុសអេហ្គាននិងអ្នកដទៃទៀត ក្រុមប្រឹក្សាភិបាលដែលអង្គុយនៅទីនេះ បន្ទាប់ពីយើងមានការប្រជុំ យប់បន្ទាប់ វាជាការពិត ខ្ញុំសូមប្រកាសនៅមុខក្រុមជំនុំ ថាអ្នករាល់គ្នានីមួយៗលែងជាអ្នក —ដែលត្រូវបានតែងតាំង។ អ្នកត្រូវបានជ្រើសរើសជាក្រុមប្រឹក្សាភិបាល ហើយ ឈ្មោះ របស់អ្នកគឺនៅក្នុងសៀវភៅ។ ត្រឹមត្រូវណាស់។

25 ហើយឥឡូវនេះពួកគេនឹងមានការជ្រើសរើសឌីខុន—ជាដើមមួយចំនួន បន្ថែម ទៀត។ ហើយបងប្រុសនេវីល នឹងហៅអ្នកទាំងនោះភ្លាមបន្ទាប់ពីកម្មវិធី នេះ ហ្នឹងហើយ ក៏នឹងរើសអ្នកខាងហេរញ្ញវត្ថុជាដើម ដូចដែលយើងបានកំណត់ ពួកជំនុំឡើង។ ស្តាល់ជីវប្រវត្តឲ្យអស់ រៀបជាស្រេច បន្ទាប់មកយើងអាចធ្វើ កម្មវិធី រីកផុសផុល ដែលនឹងមានបន្ទាប់។

26 ឥឡូវនេះ មុននឹងយើងត្រឡប់ទៅទំព័រនៅទីនេះ សម្រាប់មេរៀនថ្ងៃអាទិត្យរបស់យើង ចំពោះព្រះបន្ទូលដ៏អស្ចារ្យនេះនៃព្រះដ៏រស់ ចូរយើងឱនក្បាលចុះបន្តិចខណៈពេលដែលយើងនិយាយទៅកាន់អ្នកនិពន្ធសៀវភៅនេះ។ ហើយញែករាល់គំនិតនិងអ្វីទាំងអស់ដែលជាភាពផ្ទុយគ្នា ដែលនាំឲ្យអ្នកបាត់បង់ព្រះពរ។

ចូរអធិស្ឋាន។

27 ព្រះដ៏បរិសុទ្ធនិងសុចរិតបំផុតអើយ នៅក្នុងវត្តមាននៃព្រះពរក្នុងខែសីហានេះ ទូលបង្គំសូមចូលមក ថ្វាយជីវិត ព្រមទាំងព្រលឹង—ទាំងរូបកាយ ទាំងការថ្វាយ បង្គំនិងទេពកោសល្យរបស់យើងដល់ទ្រង់។ ហើយអ្វីទាំងអស់ដែលយើងមាន យើងថ្វាយទៅទ្រង់។ ហើយពេលទ្រង់ទតមកទូលបង្គំព្រះអង្គអើយ បើមានអំពើ បាបណាដែលមិនទាន់បានសារភាព យើងនឹងសូមទ្រង់ឱព្រះអម្ចាស់ជាព្រះ ថា ទ្រង់នឹងសម្អាតដោយព្រះលោហិតនៃព្រះរាជបុត្រារបស់ទ្រង់ ព្រះយេស៊ូវទៅគ្រប់ កន្លែង។ ដើម្បីឲ្យដឹងថានៅក្នុងខ្លួនយើងគឺមិនល្អឥតខ្ចោះ ហើយមិនអាចមាន ជីវិតអស់កល្បដោយខ្លួនឯង។ ប៉ុន្តែយើងពឹងផ្អែកទាំងស្រុងទៅលើឈាមដ៏ថ្លៃ វិសេសរបស់ទ្រង់ និងព្រះគុណរបស់ទ្រង់ដើម្បីអនុវត្តក្នុងជីវិតយើង ដែលជាមនុស្សមានបាបមិនសក្តិសម អាចមកដោយក្លាហាននៅថ្ងៃណាមួយ ទៅក្នុងវត្តមានរបស់ទ្រង់ នាំយើងមកដោយព្រះលោហិតរបស់ព្រះយេស៊ូវគ្រីស្ទ។ ដែលទ្រង់កាលពីអតីតកាលបានសន្យាដោយព្រះលោហិតនៃព្រះរាជបុត្រាតែមួយរបស់ទ្រង់ថា "តាមរយៈទ្រង់បើយើងលន់តួបាបយើងវិញ នោះនឹងត្រូវបានរាប់ជាសុចរិតដោយសារព្រះគុណរបស់ទ្រង់។"

28 ហើយឥឡូវនេះយើងទូលសូម ព្រះអង្គអើយ សូមទ្រង់អត់ទោសយើងរាល់គ្នារាល់កំហុស រាល់អំពើបាបនៃការរំលងឬការលុបចោលការរំលង ថាបើមានអំពើអាក្រក់ណាមួយ គំនិតដែលកាត់ផ្តាច់ព្រលឹងវិញ្ញាណយើង ដោយព្រួញភ្លើង របស់អារក្ស សូមទ្រង់បណ្តេញខ្មាំងសត្រូវដ៏អាក្រក់នៃទ្រង់ ហើយនិងរាស្ត្ររបស់ ទ្រង់ចេញ។

29 ហើយសូមទ្រង់ចាត់ព្រះវិញ្ញាណបរិសុទ្ធដើម្បីចាប់យកព្រះបន្ទូលនៅពេលនេះ ដែលយើងបានប្រគល់ខ្លួនយើង ធ្វើជាឧបករណ៍សម្រាប់ទ្រង់ មានបន្ទូលតាមរយៈ យើង ហើយស្តាប់តាមរយៈយើងនូវព្រះបន្ទូលរបស់ទ្រង់។ ហើយសូមឲ្យយើង បញ្ជូនវាបន្តដូចជាទ្រង់បានផ្តល់ឲ្យដែរ ហើយថ្វាយកន្លែងនេះ នៅថ្ងៃនេះ

ដោយ អារម្មណ៍ថាយើងនឹងតម្រង់ទៅរកមាគ៌ារបស់ព្រះគ្រិស្ត។ ថាយើងអាចនឹងល្អ ប្រសើរជាងមុន សមនឹងការថ្វាយបង្គំនៅយប់នេះនិងថ្ងៃស្អែក ដោយសារការយាងមកនៃព្រះវិញ្ញាណបរិសុទ្ធ។

30 សូមប្រទានពរដល់បងប្អូនយើងគ្រប់ទីកន្លែង ក្រុមជំនុំនៅទូទាំងពិភពលោក ជាអ្នកកំពុងតែកាន់ព្រះបន្ទូលនៃជីវិតនៅក្នុងថ្ងៃដ៏អាក្រក់នេះ។ យើងមានអារម្មណ៍ថា មិនមានពេលច្រើនទេដើម្បីធ្វើការនេះ ពីព្រោះវេលា យប់កាន់លឿន។ សង្គ្រាមត្រូវបានរសាត់អណ្ដែតម្ដងទៀត។ អំពើអាក្រក់បាន មកដល់ ហើយយើងអធិស្ឋានសូមទ្រង់អនុញ្ញាតឲ្យយើងធ្វើការលើសជាងពេលមុនៗ។ សម្រាករាងកាយនឿយហត់របស់យើង ព្រះអង្គអើយ ហើយបញ្ជូន យើងទៅក្នុងសមរភូមិវិញ។ ត្បិតយើងសូមនៅក្នុងព្រះនាម នៃព្រះអម្ចាស់យេស៊ូវ ហើយក្នុងទ្រង់យើងអធិស្ឋាន។ អាម៉ែន។

31 យើងនឹងបើកព្រះគម្ពីរ នៅព្រឹកនេះ ទៅជំពូកទី—ទី11 នៃព្រះគម្ពីរហេព្រើរ

32 នៅរាត្រីថ្ងៃព្រហស្បតិ៍ យើងបានអធិប្បាយនៅក្នុងជំពូកទី7 នៃព្រះគម្ពីរហេព្រើរ អំពីរ "មីលគីស្សាដិកដែលគ្មានឪពុកនិងគ្មានម្ដាយ គ្មានការចាប់ផ្ដើមឬថ្ងៃបញ្ចប់នៃជីវិត។"

33 ហើយខ្ញុំបានគិតថា ប្រហែលជាព្រឹកនេះ គួតែបើកសៀវភៅគម្ពីរដ៏អស្ចារ្យនេះ ម្ដងទៀត ដែលមានប្រវត្តិខាងក្រោយដែលយើងចង់និយាយ នៅក្នុងការអានពីមុន។ ហើយរំលងជំពូកទី10 និងជំពូកទី 9 ដែលជាច្បាប់នៃការថ្វាយ យើងនឹងចូលមកកន្លែងនៃ "សេចក្ដីជំនឿ។" ហើយនៅទីនេះក្នុងគម្ពីរហេព្រើរជំពូកទី11 ហើយចាប់ផ្ដើមជាមួយខ23 យើងអានវាដូច្នេះ

> *ដោយសារសេចក្ដីជំនឿ កាលម៉ូសេបានកើតមក នោះឪពុកម្ដាយបានលាក់លោកទុក៣ខែ ឥតមាននឹកខ្លាចដល់បញ្ញត្តរបស់ស្តេចឡើយ ពីព្រោះបានឃើញថាជាកូនថ្លោសល្អ*
>
> *ដោយសារសេចក្ដីជំនឿ លុះលោកធំហើយ នោះលោកមិនព្រមឲ្យគេហៅខ្លួន ជាកូនរបស់បុត្រីផារ៉ោនទេ*
>
> *លោកស៊ូរងទុក្ខលំបាកជាមួយនឹងរាស្ត្ររបស់ព្រះ ជាជាងមានសេចក្ដីអំណរខាងអំពើបាប ដែលនៅតែ១ភ្លែតនោះវិញ*

*ដោយបានរាប់សេចក្ដីដំនៀលដែលគេតិះដៀលដល់ព្រះគ្រីស្ទ ទុកជាទ្រព្យសម្បត្តិប្រសើរជាងអស់ទាំងរបស់ថ្លៃវិសេសនៅស្រុកអេស៊ីព្ទ ដ្បិតលោកសំឡឹងចំទៅឯរង្វាន់វិញ*

*ដោយសារសេចក្ដីជំនឿ នោះលោកក៏ចេញពីស្រុកអេស៊ីព្ទទៅ ឥតកោតខ្លាចដល់សេចក្ដីកំហឹងនៃស្ដេចឡើយ ដ្បិតលោកបានកាន់យ៉ាងខ្ជាប់ខ្ជួន ហាក់ដូចជាឃើញព្រះដ៏មើលមិនឃើញដែរ។*

34 ខ្ញុំចង់ដាក់ប្រធានបទនៅព្រឹកនេះគឺ "ការជ្រើសរើសដោយសេចក្ដីជំនឿ។" ហើយ ខ្ញុំចង់ស្រង់យកអត្ថបទមួយ ចេញពីពាក្យបីដំបូងនៃជំពូក23 ដោយសេចក្ដីជំនឿ កាលម៉ូសេ។ ហើយ "ការជ្រើសរើសដោយសេចក្ដីជំនឿ" អ្វីដែលយើងចាំបាច់ជាងគេ យើងត្រូវតែជ្រើសរើសដោយសេចក្ដីជំនឿ។ ហើយយើងនឹងរកឃើញការទាំងនោះនៅក្នុងម៉ូសេ អ្វីដែលយើងឃើញញឹក ញាប់នោះគឺ ដោយសារសេចក្ដី ជំនឿ។ មិនមែនដោយមើលឃើញទេ តែដោយសារជំនឿ។

35 ហើយហេតុដែលខ្ញុំជ្រើសរើសអត្ថបទនេះ សម្រាប់ពួកជំនុំនៅក្នុងរដ្ឋនេះ ព្រឹកនេះនៅក្នុងយើង សូម្បីនៅជុំវិញយើង...និងនៅក្នុងសាលាយើងមានការបង្រៀនផ្នែកវិទ្យាសាស្រ្តជាច្រើន។ ដោយសារការនេះយើងបានទាញមនុស្សចេញឆ្ងាយ ពីក្ដីជំនឿ។ ឥឡូវនេះ សេចក្ដីជំនឿមិនបានបង្ហាញដោយវិទ្យាសាស្រ្តទេ។ សេចក្ដីជំនឿគឺជាអ្វី ដែលវិទ្យាសាស្រ្តមិនអាចមើលឃើញ។ ហើយយើង...ប្រសិនបើយើងបាត់បង់ ជំនឿដ៏អស្ចារ្យនេះ នោះយើងស្ថិតនៅក្នុងភាពងងឹត ទាំងស្រុងវា...មិនថាយើង បានទទួលការអប់រំល្អប៉ុណ្ណា យើងអាចពន្យល់ព្រះ បន្ទូលនៃព្រះប៉ុណ្ណា វាសមតាម វិធីនៃការជឿផ្ទាល់របស់យើង។

36 គ្មានផ្លូវណាដែលអាចផ្គាប់ព្រះទ័យព្រះបានឡើយ មានតែតាមរយៈសេចក្ដីជំនឿប៉ុណ្ណោះ។ ព្រះគម្ពីរបញ្ជាក់យ៉ាងច្បាស់ថាមានតែផ្លូវនោះទេ គឺជាសេចក្ដីជំនឿ។ "បើគ្មានជំនឿ" បទគម្ពីរចែងថា "គ្មានវិធីណាផ្គាប់ព្រះហឫទ័យព្រះបានឡើយ។"

37 ដូច្នេះ បើសិនជាសេចក្ដីជំនឿមិនយល់ព្រមនឹងវិទ្យាសាស្រ្ត ហើយវិទ្យាសាស្រ្តមិនយល់ព្រមជាមួយនឹងសេចក្ដីជំនឿទេ។ នោះធ្វើឲ្យពួកគេស្ថិតនៅគម្លាតពីគ្នាទៅវិញទៅមក បន្ទាប់មកយើងត្រូវតែជ្រើសរើសដូចលោកម៉ូសេបានធ្វើ។ ដោយសារជំនឿយើងជឿ!

38 ឥឡូវ បើសិនជាយើងបាត់បង់សេចក្តីជំនឿ នោះសេចក្តីអធិស្ឋានរបស់យើង ក៏មិនបានឆ្លើយតបពីទ្រង់ដែរ។ "ដ្បិតអ្នកដែលមកឯព្រះ មុនដំបូងត្រូវតែជឿ ថាទ្រង់ជាព្រះ ហើយនឹងមានរង្វាន់ដល់អ្នកដែលស្វែងរកទ្រង់។" ដូច្នេះ បើសិនជាយើងបាត់បង់ជំនឿ សេចក្តីអធិស្ឋានរបស់យើងត្រូវបានទុកជាមោឃៈ។ យើងមិនមាន កន្លែងណាសោះ។

39 ដូច្នេះវាគឺជាអ្វីដែលយើងអាចគិត នៅព្រឹកនេះ គឺដើម្បីកាន់ខ្ជាប់នូវសេចក្តីជំនឿ។ បន្ទាប់មកបើយើងបាត់បង់ជំនឿ នោះក្តីសង្ឃឹមរបស់យើងទាំងអស់ នឹងរលាយបាត់ទៅ។ ហើយប្រសិនបើយើងបាត់បង់ជំនឿ ក្តីពិតខាងវិញ្ញាណរបស់យើងទាំងអស់ត្រូវបានបាត់បង់។ ព្រោះអ្នកមិនអាចមានក្តី ជំនឿលើរឿងដែលអ្នកមើលឃើញបានទេ ព្រោះអ្វីដែលអ្នកឃើញទាំងអស់គឺអាចវិនាស។

40 បើសិនជាយើងមើលទៅកាន់អ្នកធំ អ្នកដឹកនាំធំៗ ឬក្រុមជំនុំច្រើននាក់ ពួកគេទាំងអស់នឹងត្រូវវិនាសនៅថ្ងៃមួយ។ ហើយប្រសិនបើយើងមើលទៅប្រទេសមហាអំណាច ឬអាវុធដ៏អស្ចារ្យ ពួកគេទាំងអស់នឹងវិនាសទៅថ្ងៃណាមួយ។ ហើយបន្ទាប់មកយើងត្រូវតែរស់ដោយសេចក្តីជំនឿ នៃរឿងទាំងនោះដែលវិទ្យាសាស្ត្រមិនបានប្រកាស។ វាដោយក្តីជំនឿដែលយើងជឿ។

41 ឥឡូវនេះយើងបាត់បង់សិរីល្អរបស់យើងបើសិនជាយើងបាត់បង់ជំនឿ។ ឥឡូវ ប្រសិនបើយើងចេញឆ្ងាយពីក្តីជំនឿ នោះយើងនឹងធ្វើឲ្យក្រុមជំនុំចូលទៅក្នុងវិស័យបញ្ញាមួយ។

42 ហើយមនុស្សភាគច្រើន បានគិតបែបនោះ ដោយសារតែក្រុមជំនុំមានទ្រង់ទ្រាយធំ ហើយពួកគេមានព្រះវិហារស្អឹមស្អៃ ដែលជាវិហារដ៏អស្ចារ្យហើយធំ មានមនុស្សស្លៀកពាក់ស្អាតៗ សង្ហារស្រស់សោភា ជាអ្នកមានហិរញ្ញវត្ថុច្រើន ដែលពួកគេអាចមានលទ្ធភាពទិញរបស់គ្រប់យ៉ាង យើងជាញឹកញាប់ គិតថាវាការបើកសម្តែងដែលព្រះវិហារគួរតែជាការបើកសម្តែងបែបនោះ។ ឬយើងជារឿយៗ សំដៅទៅអ្នកដឹកនាំផ្សេងៗដែលធ្វើបេសកកម្ម ហើយបានប្រមូលហ្វូងមនុស្សដ៏ច្រើនសន្ធឹកមក ហើយយើងជួនកាលគិតថាពួកគេគឺជាសញ្ញានៃការបើកសម្តែង។ ប៉ុន្តែនោះមិនមែនជាក្តីពិតទាំងអស់ទេ។ នោះជាការបើកសម្តែងរបស់មនុស្ស។

43 ប៉ុន្តែការបើកសម្តែងពិតប្រាកដកើតឡើងដោយការធ្វើតាមព្រះហឫទ័យព្រះ។ ឃើញទេ? មិនថាវាសល់តែមួយឬមួយក្តាប់ទេ។ មិនថាក្រុមជំនុំតិចឬច្រើន វាមិន

មែនជាបញ្ហានោះទេ។ មិនថាគាត់ជាអ្នកប្រសព្វខាងវោហា ឬគ្រាន់តែបុរសម្នាក់ដែលមិនស្គាល់ អេប៊ីស៊ី វាមិនសំខាន់ទេ។ វាអាស្រ័យលើសារដែលគាត់បាននាំយកមក ថាវាត្រូវបានបើកសម្តែងដោយព្រះបន្ទូលនៃព្រះ ឬវាត្រូវបានបើកសម្តែងដោយគំនិតរបស់មនុស្ស?

44 មនុស្សខ្លះអាចមានការបើកសម្តែងដោយសារមានវាគ្មិនដែលប្រសព្វនិយាយ។ តែនោះក៏មិនបញ្ជាក់ថាវាត្រឹមត្រូវដែរ។ ជួនកាលពួកគេត្រូវបានបើកសម្តែងដោយ សារមនុស្សនោះ គាត់ជំនាញទើបគេអាចយកទស្សនៈរបស់គាត់មកអនុវត្ត។ នោះក៏មិនមែនមានន័យថាវាមកពីព្រះដែរ។ ឃើញទេ?

45 មានតែតាមរយៈព្រះបន្ទូលដ៏មានពររបស់ព្រះ ដែលគង់នៅអស់កល្បជានិច្ចប៉ុណ្ណោះ ទើបយើងអាចទទួលការបើកសម្តែងហើយបានប្រទានដោយ ព្រះវិញ្ញាណបរិសុទ្ធ។ យើងទទួលវា ដោយសារសេចក្តីជំនឿ។

46 ឥឡូវនេះយើងគិតពីម៉ូសេវិញ និងពេលវេលាដ៏អស្ចារ្យនៃជីវិតរបស់គាត់។ ហើយយើងអានត្រឡប់មកវិញ ពីកំណើតរបស់គាត់ ពីរបៀបដែលព្រះបាន ថែរក្សាគាត់ តែមានពេលមួយក្នុងជីវិតរបស់លោកម៉ូសេ ជាកន្លែងនៃសម័យនៃការ រើសតាំង។ បើយើងអានត្រឹមត្រូវ យើងរកឃើញថាគាត់គឺជាកូនរបស់បុត្រីផារ៉ោន។ និងជាអ្នកស្នងរាជ្យបន្តហើយនឹងក្លាយជាផារ៉ោនបន្ទាប់នៅប្រទេសអេហ្ស៊ីប។ ដូច្នេះគាត់កត់សម្គាល់នៅពេលគាត់មើលជុំវិញ បន្ទាប់ពីគាត់ពេញវ័យអាចធ្វើជាអ្នកគ្រប់គ្រងបាន ហើយក៏មានទាសករធ្វើការក្នុងរណ្តៅភក់។ ហើយម៉ូសេនៅពេលដែលគាត់សម្លឹងតាមបង្អួចរាជវាំង ទៅលើទាសករដូចគ្នាដែលស្តេចផារ៉ោនបានមើល ប៉ុន្តែអ្វីដែលជាភាពខុសគ្នា មាននៅក្នុងការសម្លឹងមើល។

47 ខ្ញុំចង់ផ្តោតគំនិតនោះ នៅព្រឹកនេះបន្តិច ហើយសូមឲ្យព្រះវរបិតានៃស្ថានសួគ៌នាំយកដាក់ក្នុងចិត្តគ្រប់គ្នានៅទីនេះពេលទៅដល់ផ្ទះវិញ។ ពីរបៀបដែលអ្នកសម្លឹងមើលអ្វីផ្សេងៗ តើអ្វីជាភាពខុសគ្នា។

48 អ្នកផ្សាយដំណឹងល្អដ៏អស្ចារ្យគឺ លោកចនអេសស្គាល់ ដែលផ្លាស់ប្រែដោយព័ន្ធកិច្ចរបស់បងប្រុសប៊ូសស្វត់ ជាម្នាក់ដែលអ្នករាល់គ្នាភាគច្រើនចាំបានកាល ពីឆ្នាំមុន ពីមនុស្សចាស់ឈ្មោះគ្លូរីបាន់។ គាត់បាននិយាយថា មានថ្ងៃមួយគាត់ កំពុងធ្វើដំណើរ មុនពេលដែលក្រុមការងារនិងភរិយាជាទីស្រឡាញ់របស់គាត់ស្លាប់។ ពួកគេរស់នៅក្នុងរដ្ឋឡាសាលលី ឡូរៀន ប្រទេសបារាំង។

ហើយខ្ញុំ មានឯកសិទ្ធិធ្វើដំណើរទៅកន្លែងដដែលនោះ។ ហើយមគ្គុទេសក៏បាននាំពួកគេ ចេញពីសួនច្បារហើយបង្ហាញពួកគេនូវរបស់ផ្សេងៗ។ ហើយពួកគេបានមកមើល រូបចម្លាក់របស់ព្រះយេស៊ូវគ្រីស្ទ។ រូបនៃការឆ្កាង។ ហើយលោកអេសស្ដាល់បាន ឈរមើល ជាមួយភរិយារបស់គាត់ ហើយក្នុងដួងចិត្តពួកគេបានរិះគន់ ពីអ្វីដែល វិចិត្រករឬជាងចម្លាក់មាននៅក្នុងគំនិតរបស់គេ នៅពេលដែលពួកគេដាក់ថ្មសិត ជារូប មើលទៅគួរតែគួរឲ្យខ្លាច ដែលវាតំណាងឲ្យការរងទុក្ខ និង សេចក្ដីស្រឡាញ់ការអាណិតនៃព្រះអម្ចាស់យេស៊ូវ ចុះហេតុអ្វីបានជាធ្វើឡើងស្អាតគួរឲ្យចាប់អារម្មណ៍ដូច្នេះ។ ហើយមគ្គុទេសក៏បានមកដល់លោកអេសស្ដាល់ ហើយគាត់បាននិយាយថា "ខ្ញុំគិតថាអ្នកកំពុងតែរិះគន់រូបសំណាករបស់ព្រះអម្ចាស់យេស៊ូវ។"

គាត់ឆ្លើយថា "បាទពិតហើយ។"

49 គាត់និយាយថា "ខ្ញុំមិនភ្ញាក់ផ្អើលទេ ព្រោះមនុស្សភាគច្រើនសម្លឹងមើលវាដំបូង គេរិះគន់វា។"

50 ហើយលោកអេសស្ដាល់បាននិយាយថា "ហេតុអ្វីបានជាខ្ញុំមិនអាចមើលឃើញ ភាពអាណិតឬការបើកសម្ដែងណាមួយ ពីការសម្លឹងមើលរឿងបែបនេះដូច្នេះ ខ្ញុំឆ្ងល់ថាហេតុអ្វីបានជាអ្នកចំលាក់ទាំងអស់ធ្វើបែបនេះ។"

51 "ហើយអ្នកចំលាក់..." បាននិយាយថា "លោកអេសស្ដាល់ រូបសំណាក់នេះ មិនជាអ្វីទេ ហើយជាងចម្លាក់គាត់ធ្វើរឿងត្រឹមត្រូវនៅក្នុងចិត្តរបស់គាត់។ ប៉ុន្តែ កន្លែងដែលមានបញ្ហាគឺនៅជាមួយអ្នក។ វាគឺពីរបៀបដែលអ្នកសម្លឹងមើលវា។" ហើយគាត់បានទាញដៃគាត់និងប្រពន្ធរបស់គាត់ ហើយនាំពួកគេចុះទៅខាងក្រោមនៃរូបឈើឆ្កាងដែលបាននិយាយនោះ។ គាត់បាននិយាយថា "ឥឡូវនេះលោកអេសស្ដាល់សូមមើលចុះ។" ហើយនៅពេលគាត់ក្រឡេកមើលទៅ គាត់បាន និយាយថាបេះដូងគាត់ចង់គាំង។ តើមានភាពខុសគ្នាយ៉ាងណា ដែលឈរនៅ ទីនោះហើយមើលវា*តាមវិធី*នោះ ហើយដែលមើលវាតាមវិធីដែលគួតែមើល។

52 ហើយនោះជាវិធីដែលព្រះមើល។ ក៏ជារបៀបនៃសេចក្ដីជំនឿដែរ។ វាជារបៀបដែលអ្នកសម្លឹងមើល។ បើអ្នកសម្លឹងមើលវាជាប្រភេទនៃព្រះគម្ពីរប្រវត្តិសាស្រ្តមួយ។នៃអ្វីមួយដែលនៅសម័យបុរាណនោះ អ្នកនឹងមិនអាចទទួលបាន តម្លៃពិត

នៃព្រះគម្ពីរទេ។ អ្នកត្រូវតែលុតជង្គង់របស់អ្នកចុះហើយគោរពបទបញ្ញត្តិនៃព្រះគម្ពីរនេះ ហើយមើលវាតាមរយៈភ្នែកនៃព្រះវិញ្ញាណបរិសុទ្ធ។

53 ខ្ញុំចង់សួរអ្នកស្តាប់នៅព្រឹកនេះ។ តើអ្វីដែលល្អ ដែលព្រះនៃប្រវត្តិសាស្ត្រ ធ្វើនៅថ្ងៃនេះ បើទ្រង់មិនមែនជាព្រះដដែលនោះ? តើព្រះទ្រង់ល្អយ៉ាងណា ដែលបាននាំលោកម៉ូសេហើយធ្វើការអស្ចារ្យជាមួយគាត់ ដូចទ្រង់ធ្វើហើយ តើមានអ្វីល្អសសម្រាប់យើងដែលសិក្សាអំពីព្រះ តើទ្រង់មិនមែនជាព្រះតែមួយ នៅថ្ងៃនេះទេឬ? តើព្រះទ្រង់ល្អយ៉ាងណាដែលអាចរំដោះចេញពីឡភ្លើង កូនចៅ ហេព្រើរ តើទ្រង់មិនមែនជាព្រះដដែលសព្វថ្ងៃនេះទេឬ? តើព្រះទ្រង់ល្អយ៉ាងណា ដែលបានវិនិច្ឆ័យរវាងអ្វីដែលត្រូវនិងខុស ក្នុងសម័យកាលកន្លងទៅហើយ ទាំង ដាក់ទណ្ឌកម្មដល់អ្នកប្រព្រឹត្តខុសហើយប្រទានពរដល់អ្នកសុចរិត តើទ្រង់មិនមែន ជាព្រះដដែលសព្វថ្ងៃនេះទេឬ? តើយើងទៅព្រះវិហារដើម្បីអ្វី? ហេតុអ្វីបានជាយើង ជៀសពីរឿងទាំងឡាយនៃលោកិយ បើទ្រង់មិនមែនជាព្រះដដែលនៃការជំនុំជំរះ ដដែលនោះហើយមានបញ្ញាញាណដូចគ្នាដដែលនោះ? តើព្រះទ្រង់ល្អយ៉ាងណា ដែលបានចាប់ដៃរបស់ស្ត្រីដែលមានជម្ងឺគ្រុនក្តៅ ហើយជម្ងឺគ្រុននោះបានជាសះ ស្បើយ តើទ្រង់មិនមែនជាព្រះដដែលនៅសព្វថ្ងៃនេះទេឬ? តើល្អយ៉ាងណាដែល បានបម្រើព្រះដែលអាចហៅមិត្តរបស់ទ្រង់ឲ្យចេញពីផ្នូរ បន្ទាប់ពីបានស្លាប់អស់ រយៈពេលបួនថ្ងៃហើយ តើទ្រង់មិនមែនជាព្រះដដែលនៅសព្វថ្ងៃនេះទេឬអី?

54 ដោយសារសេចក្តីជំនឿ យើងជឿថានៅថ្ងៃដ៏រុងរឿងទ្រង់នឹងហៅយើងចេញពីផែនដីនេះ ទោះបីជាយើងក្លាយជាផេះតែមួយស្លាបព្រាក៏ដោយ។ តើយើងមានអ្វីជាភស្តុតាង? យើងមិនត្រូវការភស្តុតាងទេ។ យើងជឿវា។ យើងមិនសុំឲ្យបង្ហាញភស្តុតាងអ្វីនោះទេ យើងសុំឲ្យគ្រាន់តែជឿ។

55 ដោយសារសេចក្តីជំនឿលោកម៉ូសេបានធ្វើ ដូច្នេះ-និង-ដូច្នេះ ដូចមានចែងទុកក្នុងគម្ពីរមែន។ ហើយកាលម៉ូសេជាក្មេងប្រុសនៅឡើយ លោកបានមើលតាមបង្អួចព្រះរាជវាំងនៅទាសករទាំងនោះ គាត់បានឃើញក្រុមទាសករ ក្រៀមក្រំនិងកខ្វក់ដូចគ្នាដែលស្តេចផារ៉ោនបានឃើញ។

56 ហើយនៅពេលដែលផារ៉ោនសម្លឹងមើលរវាងពួកគេនិងពួកអេស៊ីព្ទ។ ពួកគេគ្មាន អ្វីទាំងអស់ គ្រាន់តែជាក្រុមទាសករល្អគ្រាន់ឲ្យធ្វើឥដ្ឋភក់សម្រាប់ ជា

ប្រយោជន៍ នៅពេលដែលស្តេចផារ៉ោនចង់សាងសង់អ្វី។ នោះជារបៀបដែលជនជាតិអេស៊ីព្ទ និងស្តេចផារ៉ោនសម្លឹងចំពោះទាសករ។

57 ប៉ុន្តែម៉ូសេ ពេលដែលគាត់សម្លឹងទៅពួកគេ គាត់សម្លឹងខុសពីគេ។ ពេល គាត់មើលឃើញពួកគេតាមបង្អួច មានស្នាមប្រឡាក់ មានទឹកភ្នែកដែលគ្រប លើថ្ពាល់និងរាងកាយ គាត់សម្លឹងមើលទៅពួកគេថាជារាស្ត្ររបស់ព្រះ។ គាត់មិន បានមើលទៅលើពួកគេថាជាទាសករនោះទេ។ គាត់បានមើលពួកគេថាជារាស្ត្រ ដែលទ្រង់បានជ្រើសរើស។

58 ហើយអូ ខ្ញុំធ្វើដំណើរពីប្រទេសមួយទៅប្រទេសមួយ ពីជាតិសាសន៍មួយទៅ ជាតិសាសន៍មួយដើម្បីអធិប្បាយ! ចាប់តាំងពីខ្ញុំបានចាកចេញពីទ្វារនៃរោង ឧបោសថតូចនេះ ដែលមិនមែនជាច្បាប់និកាយទេប៉ុន្តែជាសេចក្តីស្រឡាញ់ មិនមែនជាសៀវភៅប៉ុន្តែជាព្រះគម្ពីរ ហើយមិនមែនជាគោលលទ្ធិតែជា ព្រះគ្រីស្ទ ខ្ញុំបានព្យាយាមសម្លឹងទៅរាស្ត្ររបស់ព្រះ អ្នកដែលគេបានបដិសេធ ឲ្យធ្វើជាអ្នករើសតាំងរបស់ព្រះ។ ខ្ញុំមិនសួរពួកគេថាតើពួកគេជាកម្មសិទ្ធរបស់រោង ឧបោសថប្រាណហាំ។ ខ្ញុំមិនសួរ ពួកគេថាតើពួកគេគឺជាពួកមេតូឌីសឬក៏ពួកប្រេសប៊ីធើរៀន ឬពួកគេជាពួក ពេនទីកុស ឬណាសារិន ឬក្រុមជំនុំបរិសុទ្ធ។ ខ្ញុំគ្រាន់តែចង់ឃើញពួកគេជារាស្ត្រ របស់ព្រះ។ ហើយឃើញការប្រព្រឹត្តរបស់ពួកគេនិងសកម្មភាពរបស់ពួកគេ គឺជា អ្នកបម្រើរបស់ព្រះអម្ចាស់ជាព្រះ។ ហើយក្នុងចិត្តខ្ញុំចង់បានការប្រកបជាមួយ ពួកគេ មិនថាពួកគេស៊ីវីលៃប៉ុណ្ណាទេ។ ខ្ញុំចង់បានការប្រកបរបស់ពួកគេ។ ខ្ញុំស្រឡាញ់ពួកគេព្រោះខ្ញុំដឹងថាពួកគេជារាស្ត្ររបស់ព្រះ។

59 ពេលខ្ញុំឃើញស្ត្រីម្នាក់កំពុងតែដើរនៅតាមផ្លូវ ដែលមានសំលៀកបំពាក់វែង។ ហើយសក់របស់នាងចងឡើងយ៉ាងស្អាតហើយ—ហើយមើលទៅការស្លៀកពាក់សមរម្យ ខ្ញុំក៏ឃើញស្ត្រីវ័យក្មេងម្នាក់ផ្សេងទៀតអាយុស្រករគ្នានិងស្ត្រីនោះ ស្លៀកខ្លី បន្តិច ហើយប្រហែលជាមានរាងស្អាតជាងស្ត្រីដែលមានសក់វែងនោះ បើយោងទៅតាមការមើលឃើញរបស់លោកិយ ប៉ុន្តែខ្ញុំយកភ្នែកខ្ញុំសម្លឹងទៅស្ត្រីដែលស្លៀកពាក់ដូចជាគ្រីស្ទានជាង។ ទោះបីជាពួកគេនឹងសើចចំអកឲ្យនាង ហើយហៅនាង ថាបុរាណជ្រុល ខ្ញុំនឹងនៅតែសម្លឹងនាងជាង។ នាងប្រហែលជាមិនស្អាតដូចក្មេង ស្រីដទៃទៀត តែនាងសម្លឹងឃើញអ្វីមួយ។ ដោយសារសេចក្តីជំនឿនាងបាន ឃើញទ្រង់ដែលមិនអាចមើលឃើញ ជាអ្នកដឹកនាំជីវិតរបស់នាង។

60 នៅពេលខ្ញុំឃើញបុរសម្នាក់ដែលបម្រើការងារ គេហៅគាត់ថា "គ្រូជំនួយ" ឬ"គ្រូគង្វាល" ឬ "អ្នកចាស់ទុំ" ពីព្រោះគាត់បដិសេធមិនជក់បារីនិងផឹកស្រាបៀរ ឬចូលរាំដូចអ្នកដទៃទៀត ហើយគាត់ត្រូវបានគេហៅថា "ចាស់បុរាណ" ចិត្តខ្ញុំ រំជួលទៅរកគាត់។ គាត់គឺជាបងប្អូនប្រុសរបស់ខ្ញុំ ក្រោមទឹកដីអេស៊ីព្ទនេះ ដែលធ្វើ ចិត្តរបស់យើងចង់ឱបក្រសោបគាត់ហើយនិយាយថា "បងប្រុសយើងគឺជាជន អន្តោប្រវេស៍និងជាអ្នកដទៃ នៅលើទឹកដីនេះហើយខ្ញុំចង់ប្រកបជាមួយអ្នក។"

លោកម៉ូសេត្រូវតែធ្វើការជ្រើសរើសដោយសេចក្ដីជំនឿ។

61 តើមានយុវជនប៉ុន្មាននាក់ដែលចង់ឡើងដើម្បីក្លាយជាកូនរបស់បុត្រីផារ៉ោន? តើមានយុវជនប៉ុន្មាននាក់ដែលចង់លោតយកឱកាសដែលលោកម៉ូសេមាន ដែលសប្បាយរីករាយនិងរំភើប ក្នុងពិភពលោកដើម្បីក្លាយស្ដេចនៃប្រទេសអេស៊ីព្ទ ដែលផែនដីទាំងមូលស្ថិតនៅក្រោមជើងគាត់ "តើល្ងង់ណាស់មែនទេ" បើតាមគំនិតរបស់យុវវ័យសម័យគាត់គិត "នៅពេលដែលម៉ូសេជ្រើសរើសកន្លែងរងទុក្ខវេទនាជាមួយរាស្ត្ររបស់ព្រះ។"

62 ហេតុអ្វីគាត់ធ្វើបែបនោះ? ដោយសារសេចក្ដីជំនឿ ពេលគាត់ក្រឡេកភ្នែកមើលលោកិយនេះ។ គាត់មើលរំលងភាពសប្បាយនៃអំពើបាប។ ហើយព្រះគម្ពីរបាន ចែងថា គាត់បានស៊ូទ្រាំដូចជាបានឃើញទ្រង់ ដែលមើលមិនឃើញនោះ ដោយសេចក្ដីជំនឿ ហើយគាត់បានធ្វើការជ្រើសរើសដើម្បីបម្រើព្រះដោយមិនគិតអ្វីដែល បានកើតឡើង។

63 វាមិនបានផ្លាស់ប្ដូរឡើយ។ យើងរាល់គ្នាអាចទៅរកសំណង់អាការល្អស្រស់។ ប្រហែលយើងអាចនឹងត្រេកអរចំពោះ ការប្រកបណាដែលមានសាឡុងអង្គុយស្រួល។ យើងអាចនឹងមានប្រជាប្រិយភាពបន្ថែមទៀតបើបានផឹកនិងជក់បារី ព្រមទាំងស្លៀកពាក់ហើយធ្វើសកម្មភាពដូចជាលោកិយធ្វើ។ ប៉ុន្តែអ្វីដែលជាបញ្ហា? អ្នកបានសម្លឹងទៅលើដោយសេចក្ដីជំនឿ អ្នកឃើញទ្រង់ដែលមើលមិនឃើញហើយបានឈរក្នុងជំហររបស់ខ្លួន ទាំងបដិសេធនិងអ្វីដែលគេហៅថាបរិសុទ្ធ—ឆ្ពោះទៅថ្ងៃនោះ។ ដោយសារជំនឿយើងឃើញទ្រង់ដែលមិនអាចមើលឃើញទទួលរងទុក្ខការបៀតបៀននិងទុក្ខវេទនា។

64 ខ្ញុំមិនបាននិយាយថាអ្នកគួរតែទទួលរងទុក្ខនោះទេ។ ខ្ញុំមិនបាននិយាយថាអ្នកគួរតែជ្រើសរើសយកក្ដីវេទនាដែរ។ វាមិនមែនជាអ្វីដែលមនុស្សត្រូវតែធ្វើ

នោះទេ។ ប៉ុន្តែបើការរងទុក្ខវេទនានៅលើផ្លូវនៃកាតព្វកិច្ចនោះចូរយើងយកវាទៅ ព្រោះវាបានមកហើយ។ ខ្ញុំមិនចង់ឲ្យអ្នកធ្វើអ្វីមួយសម្រាប់ឲ្យអ្នកដទៃសើចចំអក ទេ។ ខ្ញុំមិនចង់ឲ្យអ្នកនិយាយអ្វីដែលខុស ថា "ខ្ញុំជា...កម្មសិទ្ធិរបស់ពួកជំនុំមួយ ដែលមិន ជឿលើ*ការនេះ—និង—ការនោះ* ក្នុងលោកិយនេះ" ហើយរឿងដូច្នេះ វាគ្រាន់តែ សម្រាប់ឲ្យមនុស្សសើចចំអកឲ្យអ្នកប៉ុណ្ណោះ។ អ្នកយកវាដាក់ជាបន្ទុក លើខ្លួនឯង។ ខ្ញុំមិនបានប្រាប់ឲ្យអ្នកចេញពីទីនេះ ហើយឆ្ពោះទៅមុខអនុវត្តអ្វីដែល ធំដុំ។ ខ្ញុំមិនចង់ឲ្យអ្នកធ្វើអញ្ចឹងទេមិនដូច្នោះមនុស្សនឹងនិយាយថាអ្នកគឺ បុរាណនិយម។ អ្នកដាក់បន្ទុកលើខ្លួនឯង។ ប៉ុន្តែប្រសិនបើវានៅក្នុងផ្លូវនៃកាតព្វកិច្ចរបស់ អ្នកចំពោះព្រះ ឲ្យលោកិយនិយាយអីនិយាយទៅ។ អ្នកបន្តរស់បែបហ្នឹង។

អ្នកធ្វើការជ្រើសរើស។ មនុស្សប្រុសស្រីគ្រប់រូបត្រូវតែធ្វើបែបនេះ។

65 ចុះបើស្ដេចផារ៉ោនបានឃើញអ្វីដែលលោកម៉ូសេបានឃើញវិញ? គាត់បាន ឃើញការឈឺចាប់របស់ប្រជាជន។ គាត់ដឹងពីតម្លៃដែលត្រូវបង់។ ប៉ុន្តែដោយជំនឿ គាត់បានជ្រើសរើស ជាជាងភាពរំជើបរំជួលរបស់អំពើបាប។

66 ឧទាហរណ៍បន្តិច យុវតីក្មេងៗស្អាតៗដែលអង្គុយនៅទីនេះ។ លោកីយ និយាយទៅកាន់អ្នកថា "*ចូរធ្វើអញ្ចេក-និង-អញ្ចេក*។ អ្នកឯងស្អាតណាស់។ អ្នកមានរាងស្វែលស្អាតមែនទែន។ អ្នកគួរបង្ហាញវា។"

67 ប៉ុន្តែបងប្អូនស្រីខ្ញុំអើយ សូមរំលងការទាំងនោះហើយក្រឡេកភ្នែកមើលទៅ ទ្រង់វិញ ដ្បិតទ្រង់មានបន្ទូលថា "វាជាការគួរឲ្យស្អប់ខ្ពើមមួយសម្រាប់ស្ត្រីដែល ពាក់សម្លៀកបំពាក់ទាក់ទាញប្រុសៗ។"

68 បើប្រុសៗនៅក្នុងសហគមន៍របស់អ្នក ឬពួកស្ត្រីមួយចំនួនប្រាប់អ្នកថា "កាត់សក់វែងហ្នឹងចោលទៅ។ វាស្រស់ស្រាយជាង។ វានឹង*អញ្ចេះ អញ្ចុះ*ឬ *អីផ្សេង។*" ឬ "អ្នកនឹងប្រសើរជាងមុន។" អ្នកកុំស្ដាប់ឲ្យសោះ!

69 អ្នកងើយភ្នែកឡើង ដោយសេចក្ដីជំនឿបានឃើញទ្រង់ដែលមានបន្ទូលថា "សក់គឺជាសិរីរុងរឿងរបស់នាង ហើយនាងនឹងមិនកាត់វាទេ។"

70 បើពួកគេនិយាយថា "វានឹងមានប្រជាប្រិយភាព។ អ្នកនឹងឈរនៅក្នុង តំណែងប្រសើរជាងមុ ឬជាមួយចៅហ្វាយរបស់អ្នកប្រសិនបើអ្នកនឹងផឹកភេសជ្ជៈ

នេះ។ បើអ្នកនឹងជក់បារីដូចជាស្រ្តីដទៃទៀត អ្នកនឹងឈរក្នុងសង្គមដែល ល្អជាងអ្នកជិតខាងរបស់អ្នក។"

71 ដោយសេចក្តីជំនឿចូរក្រឡេកមើលទៅឯព្រះអង្គដែលមានបន្ទូលថា៖"រូបកាយ ដែលស្អុយរលួយនេះ អញនឹងបំផ្លាញវា។" ដោយសារសេចក្តីជំនឿយើងជឿ លើការទាំងនេះ។ វាមិនមែនជាអ្វីដែលអ្នកបានឃើញទេ។ វាជាអ្វីដែលអ្នកជឿ។ ដោយសារសេចក្តីជំនឿលោកម៉ូសេធ្វើបាន។

72 ហើយនៅពេលជំនឿចាប់ផ្តើមធ្វើការ នឹងមានវេលាដែលអ្នកត្រូវការ ការជ្រើសរើស។

73 លោកឡុតបានធ្វើកំហុសដ៏ក្រៀមក្រំដែលយើងបានធ្វើ។ ជាញឹកញាប់ យើងជ្រើសរើសអ្វីដែលល្អសម្រាប់ខ្លួនឯង។ យើងជ្រើសរើសអ្វីដែលល្អជាង។

74 ជួនកាល ឧទាហរណ៍បើមានទំនាស់តិចតួចកើតឡើងនៅក្នុងពួកជំនុំ ហើយមាននរណាម្នាក់និយាយថា "អ្នកជំនួយឬគ្រូគង្វាលកាន់ជើងខាងនេះ។" កុំមើលរបៀបហ្នឹង។ រកមើលអ្វីដែលត្រឹមត្រូវ។ យករឿងនោះចេញហើយនាំពួកគេទាំងពីររួមគ្នា។ នោះទើបត្រូវ។

75 មានការជ្រើសរើស។ ហើយយើងជ្រើសរើសសម្រាប់ខ្លួនឯង។ យើងជ្រើសរើសអ្វីដែលជាប្រយោជន៍របស់យើង។

76 ប៉ុន្តែលោកម៉ូសេបានជ្រើសរើសការឈឺចាប់និងភាពអាម៉ាស់ ដើម្បីឲ្យគាត់អាចដើរជាមួយនិងរាស្រ្តរបស់ព្រះ។ សូមគិតឥឡូវនេះ។ ស្តាប់វា។"ស៊ូរងទុក្ខវេទនាជាមួយរាស្រ្តរបស់ព្រះ ដោយបានរាប់សេចក្តីដំនៀលដែលគេតិះដៀល ហាក់បានឃើញទ្រង់ដែលមើលមិនឃើញដែរ។"

ឥឡូវ មានពេលមួយលោកឡុតត្រូវធ្វើការជ្រើសរើស។

77 ហើយក៏ប្រហែលជាព្រឹកនេះ មានបងប្អូនប្រុសស្រីខ្លះដែលអង្គុយនៅទីនេះដែលនឹងជ្រើសជម្រើសចុងក្រោយរបស់អ្នក។ អ្នកគឺជាអ្នកនៅថ្ងៃនេះ ដោយសារតែពីរបីឆ្នាំមុនអ្នកបានជ្រើសរើសដើម្បីឲ្យមានថ្ងៃនេះ។ ហើយអ្វីដែលអ្នកជ្រើសរើសឥឡូវនេះនឹងកំណត់នូវអ្វីដែលអ្នកនឹងក្លាយជានូវប្រាំឆ្នាំបន្ទាប់ពីថ្ងៃនេះ។ ប្រាំឆ្នាំបន្ទាប់ពីថ្ងៃនេះអ្នកប្រហែលធ្វើជាអ្នកផ្សព្វផ្សាយដំណឹងល្អ។ ប្រាំឆ្នាំពីថ្ងៃនេះអ្នកប្រហែលជាគ្រីស្ទានដែលមានកេរ្តិ៍ឈ្មោះ។

78 ឬប្រាំឆ្នាំបន្ទាប់ពីថ្ងៃនេះអ្នកអាចនៅក្នុងឋាននរក ដោយសារអ្នកសម្រេច ចិត្តខុស។ ប្រាំឆ្នាំគិតចាប់ពីថ្ងៃនេះអ្នកប្រហែលជាកំពុងសម្អាតកំហាក ក្នុងបន្ទប់ទឹក។ ប្រាំឆ្នាំពីថ្ងៃនេះអ្នកអាចជាស្រីពេស្យាម្នាក់នៅតាមផ្លូវ។

79 ឬក៏ អ្នកអាចជាប្រុសស្រីម្នាក់ដែល—ដែលមានកិត្តិយសក្នុងសង្គមណាមួយ ដោយសារអ្នកជ្រើសរើសសម្រាប់ព្រះគ្រីស្ទ។ ប្រាំឆ្នាំពីថ្ងៃនេះអ្នកអាចនៅក្នុងសិរីល្អ និងចូលទៅក្នុងគ្រាលើកឡើង ពីព្រោះតែជម្រើសរបស់អ្នកនៅថ្ងៃនេះ។

80 ប៉ុន្តែអ្នកត្រូវតែជ្រើសរើស។ ហើយកុំមើលអ្វីដែលអ្នកឃើញ។ ជ្រើសរើសអ្វីដែលអ្នកឃើញដោយសេចក្តីជំនឿ។ នោះហើយជារឿងតែមួយគត់ដែលនឹងរាប់ជាគួជាអ្វីដែលអ្នកជ្រើសរើសដោយ សេចក្តីជំនឿ។

81 ឡុតពេលគាត់ត្រូវធ្វើការជ្រើសរើស។ អ័ប្រាហាំផ្តល់នូវជម្រើសឲ្យគាត់។

82 ហើយព្រះទ្រង់បានប្រទានដល់អ្នកនូវជំរើសរបស់អ្នកដូចគ្នា។ "ជ្រើសរើសនៅថ្ងៃនេះ តើអ្នកនឹងបម្រើនរណា។" នៅក្នុងសួនច្បារអេដែនមានដើម—ដើមឈើនៃការដឹងខុសត្រូវនិងដើមជីវិត។ មនុស្សមានឯកសិទ្ធិជ្រើសរើស យក មួយណាដែលគាត់ចង់បាន។ ហើយក៏ដូចគ្នាដែរនៅថ្ងៃនេះ។ អ្នកមានសិទ្ធិផ្ទាល់ ខ្លួន គឺដូចជា សីលធម៌ឥតគិតថ្លៃ ដើម្បីជ្រើសអ្វីដែលអ្នកចង់បាន។

83 ដំបូន្មានរបស់ខ្ញុំចំពោះអ្នក គឺមិនត្រូវសម្លឹងមើលអ្វីដែលទំនើបនៅជុំវិញអ្នក។ និងប្រជាប្រិយភាពឬភាពរំជើបរំជួលដែលអ្នកអាចធ្វើបាន។ ប៉ុន្តែផ្ទុយទៅវិញ ដោយសេចក្តីជំនឿ សូមជ្រើសរើសទ្រង់ដែលបានសន្យាថា ថ្ងៃណាមួយទ្រង់នឹង យាងមក នឹងញែកខុសនិងត្រូវ ហើយនឹងប្រទានជីវិតអស់កល្បជានិច្ចព្រមទាំង លើកអ្នកឡើង។ មិនថាអ្នកយកមធ្យោបាយដែលត្រូវគេមើលងាយដោយ ព្រះអម្ចាស់ប៉ុន្មានទេ សូមអ្នកធ្វើជម្រើសនោះ។ មិនថាមានបញ្ហានៅក្នុងដៃ ឬមាន បញ្ហានៅក្នុងប្រទេស ឬបើមានបញ្ហានៅក្នុងព្រះវិហារ មានបញ្ហានៅក្នុងផ្ទះក្តី មិនថាជាកន្លែងណាទេ អ្នកមានជម្រើសរបស់អ្នក "ដោយសេចក្តីជំនឿខ្ញុំនឹងបម្រើ ព្រះ។ ខ្ញុំនឹងបន្ទាបចិត្តខ្ញុំក្នុងវត្តមានរបស់ទ្រង់។ ខ្ញុំនឹងដើរក្នុងផ្លូវជាមួយរាស្ត្ររបស់ ព្រះ។ ខ្ញុំបានឃើញពួកគេស្អប់ហើយបដិសេធ ទាំងបណ្តេញចេញថែមទាំងសើចឡកឡឺយ តែខ្ញុំនឹងនៅតែកាន់តំណែងរបស់ខ្ញុំ។ ខ្ញុំនឹងនៅដោយត្រឹមត្រូវ។ ហើយនៅពេលដែលពួកគេយំខ្ញុំនឹងយំជាមួយពួកគេ។ ហើយនៅពេលមានទុក្ខ

ព្រួយខ្ញុំនឹងព្រួយជាមួយពួកគេ។ របៀបដែលពួកគេរស់នៅយ៉ាងណា ខ្ញុំនឹងរស់នៅយ៉ាងនោះដែរ។"

84 ដូចជានាងណាអូមីបាននិយាយថា...ឬនាងរស់បាននិយាយទៅណាអូមីថា "ផ្លូវរបស់អ្នកម្តាយគឺជាផ្លូវរបស់ខ្ញុំ។ ផ្លូវរបស់ខ្ញុំក៏ជាផ្លូវរបស់អ្នកម្តាយដែរ។ កន្លែងណាដែលអ្នករស់នៅខ្ញុំនឹងរស់នៅ។ កន្លែងណាដែលអ្នកទៅខ្ញុំក៏ទៅទីនោះដែរ។ ព្រះដែលអ្នកបម្រើនោះនឹងជាព្រះរបស់ខ្ញុំដែរ។" រើសយកជម្រើសនោះ ទោះបីវា ទាញស្បែកអ្នកចេញពីមនៈសិការដែលគិតថាអ្នកគឺជានរណាម្នាក់។ កាត់ស្បែក ចិត្តរបស់អ្នកចេញ ហើយជ្រើសរើសផ្លូវរបស់អ្នកជាមួយព្រះអម្ចាស់ដែលគេមើលងាយនោះ ហើយស្មោះត្រង់នឹងកិច្ចការបំរើព្រះ តាមកាតព្វកិច្ចនោះ។

85 លោកឡុត បានមើលជុំវិញ។ គាត់បាននិយាយថា "ខ្ញុំនឹងជ្រើសរើស។" ហើយគាត់បានសម្លឹងឆ្ពោះទៅក្រុងសូដុម។ គាត់ឃើញវាលស្រែល្អៗ ល្អជាងអ្វីដែលអ័ប្រាហាំឃើញ និងកន្លែងដែលអ័ប្រាហាំរស់នៅ។ គាត់បានឃើញឱកាសដើម្បីហ្វូងសត្វរបស់គាត់ស៊ី អោយហ្វូងសត្វកាន់តែចម្រើនឡើង។

86 ខ្ញុំសង្ឃឹមថាខ្ញុំមិនបានធ្វើឲ្យនរណាម្នាក់ឈឺចាប់នោះទេ។ ប៉ុន្តែនោះគឺជាជំហរ នៃគ្រូគង្វាលជាច្រើនដើម្បីសម្របសម្រួលជាមួយនឹងដំណឹងល្អដោយគិតថា ពួកគេទទួលបានលុយច្រើនជាងនេះ។ ប្រងប្រុសប្រាណហាំទះដៃរបស់គាត់ បីដង—Ed.] សំបុត្រអាហារ! ខ្ញុំចង់រស់នៅលើដីដែលគ្មានជីវជាតិ បរិភោគផឹកសូដា ជាងការសម្រប លើសេចក្តីជំនឿរបស់ខ្ញុំនៅក្នុងព្រះបន្ទូល របស់ព្រះដ៏មានព្រះជន្មរស់។ ខ្ញុំនឹងយកវិធីរបស់ខ្ញុំ។

87 មានអ្នកខ្លះនិយាយថា "ប៊ីលលី តើកិច្ចប្រជុំរបស់អ្នកនឹងមានបញ្ហាអ្វី ដូចជាមានពួកពេនទីកុសជាច្រើនចូលរួម។" អ្នកដឹកនាំនិកាយដ៏អស្ចារ្យម្នាក់និយាយដូច្នេះ។

ខ្ញុំតបថា "តើនិកាយរបស់អ្នកនឹងឧបត្ថម្ភការប្រជុំរបស់ខ្ញុំឬ?"

88 កាលពីពេលមុននៅក្នុងទស្សនាវដ្តីលូក ខ្ញុំជឿជាក់ មានអត្ថបទមួយ។ ហើយអ្នកនិពន្ធបាននិយាយនៅទីនោះ អំពីអ្នកពេនទីកុស។ គាត់បាននិយាយថា "ក្រុមជំនុំពេនទីកុសគឺជាក្រុមជំនុំដែលរីកលូតលាស់លឿនបំផុតនៅក្នុង

ពិភពលោកសព្វថ្ងៃនេះ។″ ហេតុអ្វី? គឺដោយសារតែមនុស្សប្រុសស្រីបានសម្លឹងទៅឆ្ងាយ។

89 ហើយអ្នកនិពន្ធក៏សរសើរអ្នកពេនទីកុសផងដែរ។ អូ! ជាការពិតណាស់ គាត់បាននិយាយដូច្នោះ "មានអ្នកខ្លះក្នុងចំណោមពួកគេមានគំនិតបែបនោះ អញ្ចឹងទៅ។ ប៉ុន្តែពួកមេតូឌីសថ្វាយបង្គំគោលលទ្ធិ។ ពួកគេថ្វាយបង្គំព្រះដោយ លទ្ធិមួយ។ ពួកបាបទីស្ទក៏ដូចគ្នា ហើយនិងពួកប្រេសប៊ីធើរៀនផងដែរ។ ប៉ុន្តែពួក ពេនទីកុសថ្វាយបង្គំដោយព្រះគម្ពីររបស់គាត់។″

90 ដោយសេចក្ដីជំនឿយើងឃើញការសន្យា។ ខ្ញុំចាប់ឆ្នោតជាមួយពួកគេ មិនថាពួកគេមើលងាយប៉ុណ្ណា ខ្ញុំនៅតែជាម្នាក់ក្នុងចំណោមពួកគេ។ ទោះបីជា ពួកគេយកខ្ញុំជាទីលេងសើចចុះឡើង ដូចពួកអ៊ីស្រាអែលបានធ្វើក៏ដោយ ខ្ញុំមិន ចង់ឈរជាមួយហោរាក្លែងក្លាយនៅលើភ្នំម្ខាង ជាបាឡាម ហើយព្យាយាមដាក់ បណ្ដាសាអ្វីដែលព្រះបានប្រទានពរ។ ដោយសារតែ នៅក្នុងជំរុំនោះគឺជាថ្មដែល ត្រូវវាយលុកហើយបង្ហូរឈាមធ្វើជាយញ្ញបូជា ព្រមទាំងបង្គោលភ្លើង។ មិនថា បញ្ហាអ្វីដែលពួកគេជួបប្រទះ វាត្រូវបានដឹកនាំឲ្យពួកគេទទួលបានជ័យជម្នះ ពួកគេត្រូវតែចូលមកដោយព្រោះតែពួកគេជាមនុស្សដែលបានសន្យា ដែលដើរដោយសេចក្ដីជំនឿ។ ទោះបីជាពួកគេមិនមែនជានិកាយណាមួយ ពួកគេបានវង្វេងនៅជុំវិញ គេនៅតែជារាស្ត្រនៃព្រះ។ ប៉ុន្តែខ្ញុំចង់ដើរតាមផ្លូវជាមួយពួកគេ ចូលរួមនៅក្នុងជួររបស់ពួកគេ មិនមែននៅក្នុងនិកាយរបស់ពួកគេទេ ប៉ុន្តែនៅក្នុង ការប្រកបរជុំវិញព្រះបន្ទូលនៃព្រះវិញ្ញាណអស់កល្បជានិច្ច ដែលដោយសារជំនឿ ដែលខ្ញុំបានទទួលបុណ្យជ្រមុជនៃព្រះវិញ្ញាណបរិសុទ្ធ។ ព្រះជួយខ្ញុំឲ្យមាន អាកប្បកិរិយាបែបនេះ។

91 សូមចំណាំ។ នៅពេលដែលពួកគេបន្តទៅមុខ យើងឃើញថាលោកឡុតបានឃើញឱកាសសម្រាប់បំប៉នសត្វគោឲ្យធាត់។ មនុស្សភាគច្រើនសម្លឹងឃើញឱកាសរកចំណូល ក្នុងកូនសៀវភៅដាក់ហោប៉ៅ។ មនុស្សជាច្រើនមើលឃើញឱកាសនៃក្នុងការឈរក្នុងសង្គមកាន់តែប្រសើរ។ គាត់មានលទ្ធភាពរកប្រាក់ដុល្លារបន្ថែម។ គាត់មានលទ្ធភាពធ្វើជាអភិបាលក្រុង។ ធ្វើជាមនុស្សចម្លែកហើយឆ្លាតវៃជាបុរសម្នាក់គាត់បាននិយាយថា "ប្រហែលជាខ្ញុំនឹងក្លាយជាចៅហ្វាយក្រុង″ គាត់ ឃើញថាអាចទៅរួចដោយសារតែកិច្ចការទាំងនោះបានដាក់នៅចំពោះមុខគាត់។ ប៉ុន្តែគាត់មិនបានឃើញភ្លើងដែលឆេះបំផ្លាញស្រុកគាត់ទេ។ គាត់មិនបាន

ផ្សះផ្សា ខ្លួនឯង ថាស្រុកទាំងមូលពោរពេញដោយអំពើបាប ហើយព្រះទ្រង់ត្រូវតែបំផ្លាញវា។

92 ហើយនៅថ្ងៃនេះ មនុស្សព្យាយាមធ្វើការផ្សះផ្សាខ្លួនឯងដោយនិយាយថា "តើអ្នក...?"

ខ្ញុំនឹងនិយាយថា "តើអ្នកគឺជាគ្រីស្ទានឬ?"

93 ពួកគេនិយាយថា "ខ្ញុំគឺជាជនជាតិអាមេរិច។" ព្រោះមិនដឹងថាធ្វើអ្វីទៀតក្រៅពីព្យាយាមនិយាយទៅកាន់ក្អែកថាវាគឺជាកង្កែប។ មិនដឹងថាគួធ្វើអីទៀត។ [បងប្រុសប្រាណហាំទះដៃរបស់គាត់ម្ដង។]

94 នាងនឹងត្រូវបានបំផ្លាញដោយសារតែព្រះគឺយុត្តិធម៌។ ហើយបើអាមេរិចទទួល អំពើបាបរបស់នាង ព្រះដ៏យុត្តិធម៌ជាវត្តមានព្រះដ៏បរិសុទ្ធនឹងធ្វើកិច្ចការរបស់ទ្រង់ ចងភ្ជាប់ទៅនឹងការរស់ឡើងវិញនៃ—ក្រុងសូដុមនិងកូម៉ូរ៉ា ហើយសុំទោសដល់ពួកគេ ព្រោះបានដុតពួកគេដោយភ្លើង ដោយសារអំពើបាបដែលគេបានប្រព្រឹត្ត បើទ្រង់ អនុញ្ញាតឲ្យយើងទទួលវា។

95 បើទ្រង់អនុញ្ញាតឲ្យអ្នកទៅឋានសួគ៌ដោយកិច្ចការអយុត្តិធម៌របស់អ្នក នោះទ្រង់ នឹងផ្ដល់ឱកាសឲ្យអាណានាសនិងសាភីរ៉ាម្ដងទៀត។ ទ្រង់ប្រាកដជាធ្វើបែបនោះ។ ប៉ុន្តែទ្រង់សុចរិត។ អាណាន្នាសសម្លឹងឃើញតង្វាយរបស់ទ្រង់។ ពេត្រុសសម្លឹងឃើញព្រះគ្រីស្ទ។

96 ឱខ្ញុំអើយ! លោកឡុតមិនបានឃើញការបំផ្លាញកូនប្រុសស្រីគាត់នៅកន្លែងនោះទេ។

97 សព្វថ្ងៃនេះអ្នករាល់គ្នាភាគច្រើន កំពុងតែកាន់សេចក្ដីបង្រៀនទាំងនេះ អ្នកមើលមិនឃើញពីភាពអយុត្តិធម៌អនីតិជននិងការបំផ្លាញកូនចៅរបស់អ្នក។ អ្នកមិនបានឃើញកូនស្រីរបស់អ្នកនៅក្នុងផ្ទះពេស្យាចារទេ។ អ្នកមើលមិនឃើញកូនប្រុសរបស់អ្នកជាមនុស្សប្រមឹកឬនៅតុបៀរណាមួយ។

98 "ដោយសារតែនាងបានស្រោចទឹកយ៉ាងល្អ។" ហើយអំពើបាបមិនត្រូវបានប៉ះ។ គាត់មិនបានឃើញភរិយារបស់គាត់ដែលជាមេដឹកនាំនៃសង្គមទាំងមូលបានប្រែ ទៅជាបង្គោលអំបិល នៅពេលដែលគាត់កំពុងសម្លឹងមើល។ គាត់មិនបានឃើញ ការរត់ប្រកិតនិងដើងធ្មេញ ទៅទីក្រុងតូចណាមួយ ដើម្បីឲ្យ

រួចជីវិត។ គាត់មិនបាន ឃើញដូច្នោះ ដោយសារតែគាត់សម្លឹងតែអ្វីដែលគាត់បានឃើញនៅមុខគាត់។

99 ប៉ុន្តែ លោកអ័ប្រាហាំវិញ គាត់មិនបានកត់សំគាល់ពីទឹក—ថ្លាត្រចង់នោះទេ ព្រោះគាត់បានសម្លឹងទៅថ្ងៃស្អែក ដ្បិតគាត់នឹងទទួលមរដកទាំងនោះ។ គ្រីស្ទានពិតប្រាកដសព្វថ្ងៃនេះ សម្លឹងមើលការសន្យារបស់ព្រះគ្រីស្ទៈ "មានពរហើយអស់អ្នកដែលស្លូតត្រង់ ដ្បិតអ្នកទាំងនោះនឹងគ្រងផែនដីជាមរដក។" គ្រីស្ទានពិតប្រាកដ ដោយសេចក្តីជំនឿ គេសម្លឹងមើលបែបនោះ។ ប្រាប់ទ្រង់នូវអ្វីដែលអ្នកចង់ បាន។ ទ្រង់ងើបភ្នែកឡើង។ ហើយនៅពេលដែលគាត់ធ្វើបែបនោះ ព្រះទ្រង់មាន បន្ទូលថា "ទីណាដែលអ័ប្រាហាំបានដើរឆ្លងកាត់ ទឹកដីនោះគឺជាឯង" ដោយសេចក្តីជំនឿអ័ប្រាហាំធ្វើដូច្នេះ។ ជំនឿដូចគ្នាដែលលោកម៉ូសេមាន។

100 វាត្រូវបានសរសេរដោយអ្នកអត្ថាធិប្បាយម្នាក់ ដែលបាននិយាយបែបនេះ។ ខ្ញុំគិតថាវាជាពាក្យដ៏ពិរោះបំផុត។ ថាអ័ប្រា..."ម៉ូសេជ្រើសរើសរបស់ដែលល្អបំផុតនៃផែនដី ដាក់វានៅក្នុងមាត្រដ្ឋានមួយ ហើយនិងសាសនាដ៏អាក្រក់ដាក់វានៅក្នុងខ្នាតផ្សេងទៀត ហើយថ្លឹងសាសនាដ៏អាក្រក់—ជាមួយរបស់ដែលល្អបំផុតនៃផែនដី។"

101 ដូច្នេះថ្ងៃនេះផងដែរ បើសិនជាយើងត្រូវបានហៅឲ្យក្លាយជាអ្វីដែលហៅថា "អ្នកនិយមលេងសើច" ឬ "អ្នកព្យាបាលមកពីព្រះ" ឬក៏ "ហូលីរ៉ូលឡឺ" ឬអ្វីក៏ដោយដែលគេចង់ហៅ។ អ្វីដែលអាក្រក់បំផុតដែលយើងមានបាន—ថ្លឹងនិង លទ្ធភាពដែលលោកិយអាចឲ្យបាន។ មិនចង់ឲ្យគេហៅថា "ម៉ូដចាស់ៗ ពូកែកំប្លែង។" វានឹង—ថ្លឹងរបស់ល្អបំផុតដែលអារក្សមានដើម្បីផ្តល់ជូនអ្នក។ វាច្បាស់ណាស់។

102 លោកម៉ូសេបានចាត់ទុកការរងការជេរប្រមាថរបស់ព្រះគ្រីស្ទ។ គាត់បានទាយពីព្រះគ្រីស្ទ។ ក្រោយមកគាត់បាននិយាយពាក្យនៃការបើកសម្តែងដ៏អស្ចារ្យមួយចំនួនអំពីទ្រង់។ "មើល ព្រះអម្ចាស់ជាព្រះរបស់អ្នក នឹងលើកហោរាមួយដូចជាខ្ញុំ។" គាត់បានជ្រាបមុន។ គាត់ឃើញទ្រង់ជាមុន ហើយចាត់ទុកការប្រមាថមើលងាយរបស់ទ្រង់ជាទ្រព្យសម្បត្តិដែលធំជាងភាពកំប្លុកកំប្លែងនៃលោកិយនេះ។

103 មិត្តភក្តិគ្រីស្ទាន សព្វថ្ងៃនេះ តើអ្នកមិនអាចធ្វើបានទេឬ? ហើយភាពរំជើបរំជួលនិងប្រជាប្រិយភាពនៃលោកិយនេះទាំងមូល ដោយសេចក្តីជំនឿយើងឃើញ

ទ្រង់ដែលបានសន្យា។ ហើយការអាក្រក់បំផុតនៃក្រុមជំនុំសព្វថ្ងៃ នៅក្នុងគ្រប់លក្ខខណ្ឌរបស់វា នឹងនៅតែថ្លឹង—អ្វីគ្រប់យ៉ាងដែលអារក្សអាចផ្តល់ជូនអ្នក។ ប្រសិនបើយើងត្រូវបានហែកទៅជាបំណែកប្រសិនបើយើងមានការយល់ច្រឡំ និងបែកបាក់គ្នា នៅក្នុងនិកាយនិងទស្សនៈ វានឹងថ្លឹង—អ្វីដែលអារក្សផ្តល់ឲ្យអ្នក។ ប្រាកដណាស់។

104 គាត់ចាត់ទុកថាការប្រមាថមើលងាយព្រះគ្រីស្ទ ជាជាងទ្រព្យសម្បត្តិដ៏វិសេសរបស់ប្រទេសអេស៊ីព្ទ។ បន្ទាប់មកគាត់ត្រូវតែធ្វើអ្វីមួយ។ គាត់បានបោះបង់ចោលអេស៊ីព្ទ។ អូ! ខ្ញុំស្រលាញ់ពាក្យនោះណាស់។ គាត់បានបោះបង់ចោលអេស៊ីព្ទ។ ឃើញទេ គាត់បានសម្លឹងតាមបង្អួចដូចគ្នានោះ ប៉ុន្តែគាត់មើលឃើញខុសគ្នា ពីផារ៉ោន។ បើសិនជាផារ៉ោនអាចមើលឃើញទីបញ្ចប់របស់គាត់? ចុះយ៉ាងណា វិញ បើផារ៉ោនបានឃើញប្រជាជាតិរបស់លោកលង់ទឹកស្លាប់? តែម៉ូសេបានឃើញវា។ ដោយរបៀបណា? ដោយវិទ្យាសាស្ត្រ? ដោយសារសេចក្តីជំនឿ លោកម៉ូសេបានឃើញវា។ អ្វីគ្រប់យ៉ាងដែលគាត់បានធ្វើគឺដោយសេចក្តីជំនឿ ដោយសារតែព្រះបានសន្យានឹងអ័ប្រាហាំ ឪពុករបស់គាត់ ថាគាត់នឹង—គាត់នឹង ទៅទស្សនាប្រទេសនេះបន្ទាប់ពីបួនរយឆ្នាំក្រោយ ហើយនឹងនាំពួកគេចេញ។ ហើយដោយសេចក្តីជំនឿលោកម៉ូសេជឿព្រះបន្ទូលព្រះ ដែលទ្រង់មានបន្ទូល ហើយស្គាល់ខ្លួនឯង ដោយសេចក្តីជំនឿត្រូវបានជ្រើសរើសដើម្បីនាំពួកគេចេញ។ គាត់ដឹងថាគាត់នៅឯណា។ គាត់រើសយកកន្លែង នៅក្នុងរណ្តៅភក់ល្បាប់ ហើយ រាប់ការស្តីបន្ទោសនៃព្រះគ្រីស្ទជាទ្រព្យសម្បត្តិដ៏វិសេស ជាជាងអង្គុយលើបល្ល័ង្ក នៃស្រុកអេស៊ីព្ទ។ គាត់ទទួល...គាត់មិនដែលនិយាយថា "ខ្ញុំអាណិតអាសូរដល់វា ។" គាត់រើសយកកន្លែងរបស់ពួកគេ ហើយទៅជាមួយពួកគេ! សូមថ្វាយ សិរីល្អទៅ...គាត់រើសយកកន្លែងរបស់ពួកគេ។ យើងបានទៅជាមួយពួកគេ។

105 គ្មានអ្វីចម្លែកទេដែលអ្នកតែងទំនុកតម្កើងសរសេរថា៖

ខ្ញុំនឹងដើរតាមផ្លូវរបស់ព្រះអម្ចាស់។
ខ្ញុំបានចាប់ផ្តើមនៅក្នុងព្រះយេស៊ូវ ដែលនាំខ្ញុំផ្លូងឥឡូវ។
ខ្ញុំកំពុងធ្វើដំណើរទៅស្រុកកាណាន។ (ប្រាកដណាស់)

106 លោកម៉ូសេ។ វាអាចនិយាយបានថាលោកម៉ូសេ ដែលធ្វើជាកូនប្រុស របស់ស្តេចផារ៉ោនពោពេញដោយកិត្តិយសនៃលោកីយស៊ូរធ្វើជាកូនរបស់អ័ប្រាហាំ

ជាជាងកូនរបស់ផារ៉ោន។ ធ្វើជាកូនរបស់លោកអ័ប្រាហាំដែលត្រូវគេមើលងាយ ជាជាងទៅធ្វើជាបុត្ររបស់ស្ដេចផារ៉ោន។

107 ខ្ញុំចង់ក្លាយជាកូនប្រុសរបស់ព្រះអម្ចាស់យេស៊ូវ ជាមួយអ្នកបំរើរបស់ទ្រង់ ហើយដើរក្នុងផ្លូវជាមួយមនុស្សដែលគេបដិសេធនៅលោកីយនេះ ជាជាងធ្វើជាប្រធានាធិបតីនៃសហរដ្ឋអាមេរិកដ៏អស្ចារ្យនេះ ឬដើម្បីក្លាយជាអែលវីស ព្រីសលី (Elvis Presley) ឬផាតប៊ូន(Pat Boone)ឬនរណាមួយដែលចង់បានវា។ ខ្ញុំនឹងដើរតាមផ្លូវខ្ញុំ។

108 យុវតីក្មេងៗប្រាថ្នាចង់ធ្វើតាមរបៀបរបស់ពួកគេ។ ជំនួសឲ្យក្លាយជា—ក្លាយជាម៉ារី ផិកហ្វ៊ត (Mary Pickford) ឬតារាភាពយន្តដ៏អស្ចារ្យមួយចំនួនក្មេងស្រីស្អាតៗខ្លះមួយចំនួន ជ្រើសរើសដើរការមើលងាយជាមួយព្រះ។

109 ខ្ញុំចង់ក្លាយជាគ្រូគង្វាលម្នាក់ដែលឈរនៅលើវេទិកា ដោយអធិប្បាយនូវអ្វីដែលមិនអាចស្វែងរកបាន ជាទ្រព្យសម្បត្តិរបស់ព្រះគ្រីស្ទ ជាជាងក្លាយជាតារាភាពយន្តហូលីវូដឬក៏មនុស្សអស្ចារ្យបំផុតនៅលោកិយនេះ។ ប្រសិនបើខ្ញុំត្រូវញ៉ាំតិចតួចសូមអង្វរឬអ្វីដែលខ្ញុំត្រូវធ្វើ ខ្ញុំនឹងដើរតាមផ្លូវរបស់ព្រះអម្ចាស់។ ដោយសេចក្ដីជំនឿខ្ញុំធ្វើបែបនោះ។ ខ្ញុំបានថ្វាយឱកាស។ ប៉ុន្តែដោយព្រះគុណរបស់ព្រះ ខ្ញុំនៅតែមើលឃើញដោយសេចក្ដីជំនឿ។

ដោយសារជំនឿខ្ញុំអាចមើលឃើញពីចម្ងាយ។
ហើយព្រះវរបិតារបស់យើងរង់ចាំនៅលើផ្លូវនេះ។
ដើម្បីរៀបចំឲ្យពួកយើងមានទីលំនៅនៅទីនោះ។

110 អ្នកយកពន្ធលើប្រាក់ចំណូល បាននិយាយនៅថ្ងៃបន្ទាប់ថា "ហេតុអ្វីបាន ជាអ្នកធ្វើឲ្យផ្ទះអ្នកក្លាយទៅជាព្រះវិហារ? តើអ្វីដែលញ៉ាំងឲ្យអ្នកធ្វើឲ្យផ្ទះតម្លៃ ពីរ-ម៉ឺន—ប្រាំ-ពាន់ដុល្លា ទៅជារោងឧបោសថកញ្ចាស់ដូចសំរាមអញ្ចឹង?"

111 ខ្ញុំតបថា "ខ្ញុំមិនបានធ្វើវាសម្រាប់ក្រុមជំនុំទេ។" មនុស្សដែលនៅទីនោះទេតើ។ ខ្ញុំគ្មានទ្រព្យសម្បត្តិណាមួយនៅលោកិយនេះទេ។ រាល់លុយកាក់ដែលខ្ញុំមាន ខ្ញុំបាននាំយកមកព្រះវិហារនេះ។ ហេតុអ្វី? សេចក្ដីជំនឿរបស់ខ្ញុំគឺនៅលើព្រះ មិនមែននៅលើរបស់នៅលោកីយនេះទេ។ ក្ដីស្រឡាញ់របស់ខ្ញុំគឺនៅខាងលើ។ ហើយខ្ញុំជឿថាអ្នកទាំងអស់គ្នាគឺដូចគ្នា ប្រសិនបើអ្នកជាប់ជាមួយព្រះ។ វាជាការ ពិតដែលអ្នកមាន។ យើងទទួលដោយជំនឿ។ យើងដោយសេចក្ដីជំនឿ ជឿលើព្រះ។

112 លោកម៉ូសេ ត្រូវតែធ្វើការជ្រើសរើស។ ហើយបន្ទាប់មកអ្វីដែលគាត់ត្រូវធ្វើ បន្ទាប់ពីការជ្រើសរើសនោះ គឺប្រយុទ្ធប្រឆាំងនឹងសេចក្តីជំនឿ ដ្បិតគាត់មិនញញើតនិងកំហឹងរបស់ស្តេចឡើយ។ ឥឡូវ ធម្មជាតិជាមនុស្ស គាត់មានសិទ្ធិភ័យខ្លាចនូវកំហឹង។ គាត់មានសិទ្ធិខ្លាចក្រឹត្យវិន័យរបស់ស្តេច តែគាត់មិនបានខ្លាចទេ។ គាត់មិនភ័យខ្លាចព្រោះគាត់មានការងារដែលត្រូវធ្វើ ហើយគាត់មានតួនាទីជាកាតព្វកិច្ច។ ហើយគាត់មិនខ្វល់ពីអ្វីដែលស្តេចបាននិយាយទេ។ គាត់ដើរតាមផ្លូវគាត់ដដែល។

113 ឥឡូវនេះ ជាការពិតស្តេចផារ៉ោន នៅពេលដែលគាត់ឃើញការបរាជ័យ គាត់ចង់ឲ្យម៉ូសេព្រមទាំងកូនៗរបស់គាត់...ស្តេចនិយាយថា "មិនអីទេ ខ្ញុំនឹងប្រាប់ អ្នកពីអ្វីដែលខ្ញុំនឹងធ្វើ។ អ្នករាល់គ្នាអាចថ្វាយយញ្ញបូជាដល់ព្រះរបស់អ្នករាល់គ្នា នៅទឹកដីនេះបាន។"

114 នោះគឺជារបៀបដែលអារក្សធ្វើការ។ "អូ អ្នកអាចកាន់សាសនាបាន។ ហេតុអ្វីអ្នកមិនទៅហើយចូលរួមក្នុងក្រុមជំនុំខ្លះ? អ្នកមិនចាំបាច់ធ្វើអ្វីៗទាំងនេះទេ" បុរសម្នាក់និយាយទៅប្រពន្ធរបស់គាត់...

115 ប្រពន្ធនិយាយថា "ប្តីសម្លាញ់ ខ្ញុំបានសង្គ្រោះហើយ។ គ្មានម៉ាសស្ការ៉ាឬក្រែមនិងវត្ថុតុបតែងទៀតទេ។ គ្មានរបស់ទាំងនោះទៀតទេ។ គ្មានពិធីជប់លៀង។ មិនប្រឡូករឿងសង្គម។ ខ្ញុំចេញពីវាហើយ! ខ្ញុំនឹងចំណាយពេលវេលារបស់ខ្ញុំក្នុង ការអានព្រះបន្ទូលនិងថែទាំផ្ទះ។"

116 "ឥឡូវមើលចុះសម្លាញ់។ អ្នក អ្នកអាចកាន់សាសនា មិនអីទេ។ ឥឡូវនេះមើល។ អ្នក—អ្នកទៅដល់ចំណុច*នេះ*។ អ្នកទៅព្រះវិហារដែលខុស។"

117 ទេអ្នកមិនមែនទេ។ អ្នកនៅកន្លែងត្រឹមត្រូវហើយ។ ប្រសិនបើអ្នកមានគ្រូគង្វាលដែលអធិប្បាយបែបនោះដល់អ្នក អ្នកគួរតែនៅជាមួយវា។ ស្វែងរក បទគម្ពីរ ដើម្បីឲ្យដឹងថាវាត្រឹមត្រូវឬទេ។

118 "អូ" បាននិយាយថា "ចូរទៅ*ទីនេះ*។ ពួកគេមិន—ពួកគេមិនចាំបាច់ ធ្វើវានៅទីនេះទេ។ ឃើញទេ? គេមិនធ្វើដូច្នេះនៅទីនេះទេ។" នោះគឺជាវិធី..."រាងឆ្ងាយបន្តិច។" តែគាត់មិនចង់ឲ្យអ្នកចាកចេញពីទឹកដីនោះទេ។ នោះជាវិធី ដែលអារក្សធ្វើ។ វាមិនចង់ឲ្យអ្នកចាកចេញពីរឿងទាំងឡាយនៃលោកិយ៍ឡើយ។ គ្រាន់តែនាំលោកិយឲ្យចូលមកពួកជំនុំ។

119 នៅថ្ងៃផ្សេងទៀត ចុះមកតាមផ្លូវខ្ញុំបានបើកវិទ្យុរបស់ខ្ញុំ។ នោះមាន—មានបទចំរៀងមួយបទ ហើយខ្ញុំបន្តស្ដាប់ស្ទើរតែជិតចប់បទចម្រៀងនោះ មុនពេល ខ្ញុំអាចប្រាប់បានថា វាជាបទចំរៀងសាសនាឬជាអ្វី អារក្សកំពុងតែព្យាយាម ដើម្បីនាំយករឿងរបស់ព្រះជាម្ចាស់ទៅក្នុងលំដាប់របស់លោកិយ។ អ្នកមិនអាចធ្វើ ដូច្នោះបានទេ! សូមព្រះទ្រង់មេត្ដាផង!

120 ខ្ញុំមិនខ្វល់ថាមានអាល់ប៊ុមចម្រៀងប៉ុន្មានដែលអែលវី ព្រីសលី(Elvis Presley) សរសេរនោះទេ ជាចម្រៀងពិរោះៗនៃសាសនា។ អារក្សនៅតែមាននៅក្នុងគាត់។ គាត់បានបញ្ជូនក្មេងៗជាច្រើនទៅឋាននរក និងចលនាទាំងអស់ដែលខ្ញុំដឹងនៅក្នុងទូទាំងពិភពលោកសព្វថ្ងៃនេះ។ ផាត់បូននិងពួកអ្នកផ្សេងទៀតគឺជាពួកជំនុំរបស់ព្រះគ្រីស្ទ។ ព្រមទាំងអែលវីសប្រេីលី ជាពួកពេនទីកុស។ ពួកគេគឺជាយូដាសអ៊ីស្ការីយ៉ុតនៅក្នុងទម្រង់នៃអ្នកទាំងនោះ។ អារក្សបានព្យាយាមនាំយកអ្វីដែលខ្ពស់របស់ព្រះដើម្បីឲ្យពួកគេអាចច្របល់វានៅ*ទីនេះ*។ មនុស្សមិនបានសម្លឹងឆ្ពោះទៅ*ការនេះ*ទេ។ ពួកគេគ្រាន់តែសម្លឹង*ទីនេះ* ហើយនិយាយថា "មិនអីទេ វាដូចតែគ្នាទេ" វាមិនដូចគ្នាទេ។ ចេញពីទឹកដី នេះទៅ។

121 បាននិយាយថា "អ្នកអាចទៅតែពីរបីថ្ងៃ។ ហើយអ្នកទៅ នៅក្នុងស្រុក នេះហើយ។" ប្រាកដណាស់គាត់ដឹងថាពួកគេនឹងត្រឡប់មកវិញ។ បន្ទាប់មកគាត់បានរកឃើញថានឹងមិនអញ្ចឹងទេ ដូច្នេះគាត់គិតអ្វីផ្សេងវិញ។ គាត់បាននិយាយថា "ខ្ញុំនឹងប្រាប់អ្នកពីអ្វីដែលអ្នកធ្វើ។ អ្នកចេញទៅទីណាដែលអ្នកចង់ទៅ ប៉ុន្តែអ្នកត្រូវទុកប្រពន្ធកូនចៅរបស់អ្នកនិងសត្វពាហនៈទាំងអស់នៅ*ទីនេះ*វិញ។ អ្នកទុកវានៅទីនេះចុះ ហើយអ្នកចេញទៅបាន។" ព្រោះ គាត់បានដឹងថាពួកគេមានរបស់ ជាកម្មសិទ្ធិ ដែលនឹងទាក់ទាញពួកគេត្រឡប់មកវិញ។

122 ហើយនោះគឺជាអ្វីដែលអារក្សនិយាយទៅកាន់អ្នក។ ដរាបណាអ្នកផ្ទុក ផ្ដាក់ខ្លួនឯង ជាមួយរបស់នៃលោកិយនេះ អ្នកនៅតែចង់ជក់បារី។ ចង់ផឹក អ្នកចង់ស្លៀកពាក់ដូចលោកិយ ដូចជាអារក្សចង់បានដែរ។

123 ខ្ញុំបានឮជាញឹកញាប់អំពីអ្នកបែចេញ។ ខ្ញុំមិនជឿថាមានអ្នកជំនឿ ថយក្រោយច្រើនដូចការគិតរបស់គេនោះទេ។ ពួកគេគ្រាន់តែចាកចេញពី ទ្រព្យសម្បត្តិនៅអេហ្ស៊ីប ដែលទាក់ទាញពួកគេត្រឡប់មកវិញប៉ុណ្ណោះ។ ជំនឿ ថយក្រោយគឺមិនមែន

ជាអ្វីដែលពួកគេនិយាយនោះទេ។ អ្នកចាកចេញពីរបស់ជា ច្រើននៃលោកិយ ដែលល្បួងអ្នកឲ្យត្រឡប់មកវិញ។

124 បងប្រុស ខ្ញុំប្រាប់អ្នក នៅពេលដែលអ៊ីស្រាអែលបានត្រៀមខ្លួនរួចរាល់ហើយ នៅពាក់កណ្តាលអធ្រាត្រពួកគេមានអ្វីគ្រប់យ៉ាងដែលពួកគេមាននៅក្នុងលោកិយនេះ បានខ្ចប់ហើយត្រៀមខ្លួនជាស្រេចដើម្បីទៅ។

125 ព្រះទ្រង់បានបញ្ជូនការរីកផុសផុលដូច្នេះ។ យើងខ្ចប់អ្វីៗគ្រប់យ៉ាង ហើយត្រៀមជាស្រេចដើម្បីទៅ។ ការយំទួញពាក់កណ្តាលយប់បានមកដល់ "ចូរចេញទៅជួបទ្រង់ទៅ។" អ្នកគួរខ្ចប់អ្វីគ្រប់យ៉ាងជាស្រេចប្រសើរជាង។ អ្នកមិនគួមានអ្វី នៃលោកិយនេះឲ្យសោះ មកល្បួងលោមអ្នកត្រឡប់មកវិញឡើយ ខ្សែណាមួយដែលទាញអ្នកចុះ។ ខ្ចប់វា។ ចូរត្រៀមខ្លួន។ យើងនឹងទៅ។

126 ហើយអ្នកដឹងទេ? ខ្ញុំប្រាប់អ្នកថា ពួកគេមានភាពស្មោះត្រង់ចំពោះព្រះ រហូតស្តេចផារ៉ោនរំជួលខ្លាំងនៅយប់នោះ គាត់បាននិយាយថា "ចេញទៅ! ចេញទៅទៅ។ យកអ្វីគ្រប់យ៉ាងរបស់ឯងទៅជាមួយផង ចេញតៅ!"

127 ខ្ញុំពិតជាមានអំណរណាស់ ដែលមនុស្សអាចរស់នៅយ៉ាងជិតនឹងព្រះ រហូតទាល់តែអារក្សមិនដឹងថាត្រូវធ្វើអ្វីជាមួយគាត់។ ពិតណាស់។ ចេញទៅ! ចេញទៅចូរស្តាប់បង្គាប់ព្រះ!

128 ដោយសារសេចក្តីជំនឿគាត់បានឃើញការសន្យា។ អ្នកធ្វើឥដ្ឋឬមិនធ្វើ ឥដ្ឋក៏ដោយ បានដើរតាមផ្លូវជាមួយព្រះដែលគេមើលងាយនោះ។ ព្រះចៅផារ៉ោនបញ្ជាថា "យកគ្រប់យ៉ាងរបស់ឯងចេញពីទីនេះទៅ! អញមិនដឹងថាត្រូវធ្វើម៉េចជាមួយឯងទេ។" គេពិតជាស្មោះត្រង់ចំពោះព្រះ ដោយសេចក្តីជំនឿ។

129 សេចក្តីជំនឿនឹងធ្វើការអស្ចារ្យ ប្រសិនបើអ្នកនៅតែស្មោះត្រង់នឹងព្រះ។ ដោយសារជំនឿ យើងឃើញទ្រង់។

ពេលវេលាយើងមកដល់ហើយ។ ពេលវេលាកន្លងហើយ។

130 ប៉ុន្តែ ដោយសេចក្តីជំនឿព្រឹកនេះ ចូរងើបភ្នែកឡើង។ កុំមើលអ្វីនៅជុំវិញអ្នកលោកិយដ៏ទំនើបនេះ ប៉ុន្តែសម្លឹងទៅទ្រង់ដែលបានសន្យា។ ព្រះគម្ពីរបានចែងថា "យើងមិនឃើញគ្រប់យ៉ាងល្អឥតខ្ចោះទេឥឡូវនេះ តែយើងឃើញព្រះយេស៊ូវ។" អ្នកសម្លឹងមើលទ្រង់នៅព្រឹកនេះ នោះផ្លូវរបស់អ្នកនឹងបានផ្លាស់ប្តូរ។

131 ខណៈពេលដែលយើងអោនក្បាលចុះ មួយភ្លែតដើម្បីអធិស្ឋាន។ សូមព្រះអម្ចាស់បន្ថែមព្រះពររបស់ទ្រង់ដល់សារនេះ។

132 ចូរគិតនៅក្នុងចិត្តរបស់អ្នកឥឡូវនេះ។ តើអ្នកបានសម្លឹងមើលរបស់ នៅលោកិយនេះ? ដោយសេចក្តីជំនឿ តើអ្នកឃើញព្រះយេស៊ូវទេ? តើអ្នកសម្លឹង មើលប្រជាប្រិយភាពក្រុមជំនុំរបស់អ្នកឬ? តើជំហរសង្គមរបស់អ្នកជាអ្វីនៅ លោកិយនេះ? ឬ តើអ្នកឃើញព្រះយេស៊ូវដែលសោកស្តាយ នៅខាងស្តាំ នៃព្រះដ៏ខ្ពស់បំផុតជាអ្នករងទុក្ខវេទនាជួសមនុស្សសុចរិតនិងទុច្ចរិតផងឬទេ? តើអ្នកអាចងើបភ្នែកឡើង សម្លឹងទៅដើមឈើនៃជីវិតនៅទីនេះឬទេ? ចូរចោល ដើមឈើនៃវិទ្យាសាស្ត្រនិងចំណេះដឹងនេះ ហើយបម្រើទ្រង់ចុះ។

133 តើអ្នកចង់ចាំសេចក្តីអធិស្ឋាននេះ មុននឹងខ្ញុំអធិស្ឋានបានឬទេ? លើក ដៃអ្នកឡើង បើមានសំណូមពរអធិស្ឋានណាមួយដែលអ្នកត្រូវការ។ សូមព្រះ ប្រទានពរដល់អ្នក។ ទ្រង់ឃើញដៃរបស់អ្នករាល់គ្នាហើយ។

134 បើអ្នកជាមនុស្សមានបាប សូមងើបភ្នែកឡើងហើយសម្លឹងទៅឥឡូវ។ ប្រសិនបើអ្នកបានព្រងើយកណ្តើយ បើសិនជាអ្នកមានការរំសាយតិចតួចនិងរឿងតិចតួច តើមានអ្វីខុសគ្នាកើតឡើង? អ្នកនឹងស្លាប់នៅថ្ងៃណាមួយ។ ថ្ងៃណា? ប្រហែលជាថ្ងៃនេះ! អ្នកមិនដឹងទេ។ មួយម៉ោងពីពេលនេះទៅមុខ អ្នកប្រហែលទៅឋាននរកឬអ្នកអាចនៅស្ថានសួគ៌។ តែអ្នកត្រូវតែជ្រើសរើសឥឡូវនេះ។ បើមានអ្វីដែលនៅក្នុងជីវិតរបស់អ្នកដែលមិនត្រឹមត្រូវ សូមជ្រើសរើសឥឡូវដោយសេចក្តីជំនឿ។

135 អ្នកនិយាយថា "ប្រសិនបើខ្ញុំអាចចូលទៅជិតនាង! ប្រសិនបើខ្ញុំអាចចូលទៅជិតគាត់!" មិនថាអ្វីដែលពួកគេបានធ្វើសូមជ្រើសរើសជីវិត។ ជ្រើសរើសជីវិត។

136 ដ្បិត ព្រះយេស៊ូវទ្រង់មានបន្ទូលថា "បើអ្នកមិនអត់ទោសឲ្យមនុស្សដែលប្រព្រឹត្តរំលងលើអ្នក នោះព្រះវរបិតានៃឋានសួគ៌ក៏មិនអត់ទោសអំពើរំលងរបស់អ្នក ដែរ" ដូច្នេះគ្រាន់តែចូលទៅជិត។ ប្រសិនបើក្នុងចិត្តរបស់អ្នកប្រឆាំងនឹងមនុស្សណាម្នាក់ ជាអ្នកមានបាបឬជាពួកបរិសុទ្ធក្តី អ្នកស្ថិតនៅក្នុងគ្រោះថ្នាក់នៃភ្លើង នរកហើយ។

137 ឥឡូវនេះសូមងើបភ្នែកឡើង។ តើអ្នកឃើញអ្វី ឃើញសត្រូវរបស់អ្នក? ឬក៏អ្នកឃើញព្រះសង្គ្រោះរបស់អ្នក? តើអ្នកកំពុងសម្លឹងទៅអ្វីនៅព្រឹកនេះ?

138 បើអ្នកមានជម្ងឺ ហើយគ្រូពេទ្យរបស់អ្នកនិយាយថាអ្នកមិនអាចជាសះស្បើយបានទេ ចូរងើបភ្នែករបស់អ្នកឡើងសម្លឹងទៅឯឈើឆ្កាង ដែលជាកន្លែងដែលទ្រង់ត្រូវបានរងរបួសសម្រាប់ការរំលងរបស់យើង យើងបានជាដោយសារស្នាមរំពាត់ទ្រង់រង។ កុំមើលអ្វីដែលគ្រូពេទ្យនិយាយ។ គាត់ធ្វើការក្នុងវិទ្យាសាស្ត្រ។ សេចក្តីជំនឿធ្វើការក្នុងអាណាចក្រនៃព្រះវិញ្ញាណនិងព្រះ។ សូមយើងពិចារណា អំពីរឿងទាំងនេះ នៅពេលដែលអ្នកលើកដៃឡើង។ ព្រះទ្រង់ទតឃើញ។

ចូរយើងអធិស្ឋាន។

139 ឱ ព្រះដ៏អស់កល្បជានិច្ចអើយ នៅក្នុងភាពស្ងប់ស្ងាត់នៃការថ្វាយបង្គំនេះ បន្ទាប់ពីសារបានចេញទៅ សូមកុំឲ្យគ្រាប់ពូជនៃព្រះបន្ទូលទាំងនេះ ធ្លាក់លើដីថ្ម។ កុំឲ្យព្រះបន្ទូលរបស់ទ្រង់ធ្លាក់ទៅក្នុងគុម្ពបន្លា ដែលសេចក្តីខ្វល់ខ្វាយអំពីជីវិតនេះ (ដូចជាលោកឡុត) អាចរាំងខ្ទប់វានៅចុងបញ្ចប់ត្រូវបានបណ្តេញចេញវិញ។ ប៉ុន្តែ ឱព្រះដ៏មានព្រះពរអើយ សូមឲ្យវាធ្លាក់មកលើដីមានជីជាតិល្អ លើចិត្តដែលខ្មេចខ្មាំ។ ហើយមកដល់ទូលបង្គំផងព្រះអង្គអើយ ដើម្បីឲ្យទូលបង្គំទាំងអស់គ្នាបានមើលតាមកញ្ចក់របស់ទ្រង់ ហើយឃើញក្រុមជំនុំដែលគេបដិសេធព្រះអម្ចាស់យេស៊ូវ ជាមនុស្សដែលគេបដិសេធ ហើយជាផ្លូវដែលបានបដិសេធហើយយើងអាចដើរនៅក្នុងផ្លូវដ៏រុងរឿងនេះ។

140 ដូចជាលោកម៉ូសេ គាត់មិនបានដឹងថាគាត់ទៅទីណាទេ។ ប្រជាជនមិនបានដឹងកន្លែងដែលពួកគេកំពុងទៅឡើយ។ ពួកគេមិនបានដឹងពីផ្លូវដែលត្រូវទៅនោះទេ។ ពួកគេទើបតែចាប់ផ្តើម។

141 ហើយឱព្រះអម្ចាស់ជាព្រះ ដូចជាបទចំរៀងដ៏ពិរោះនេះចាប់ផ្តើមលេង ដោយសេចក្តីជំនឿយើងអាចមើលឃើញពីទីឆ្ងាយ។ សូមឲ្យវាមកឥឡូវ សូមឲ្យ មនុស្សប្រុសស្រីនៅទីនេះ ឈប់គិតអ្វីដែលលោកិយនិយាយ ឬពួកគេទៅរបៀបណា។ សូមឲ្យពួកគេបានក្រោកឡើងដោយវិញ្ញាណហើយចេញទៅ។

142 ម៉ូសេបានដើរតាមពន្លឺហើយវាបាននាំគាត់ទៅកាន់ទឹកដីសន្យា។ ដោយមិនដឹងថាគាត់ទៅទីណាទេ ប៉ុន្តែគាត់បានដើរនៅក្នុងពន្លឺ ទៅទឹកដីដែលមានភាពល្អជាងថ្ងៃ។

143 សូមប្រទានពរព្រះអង្គអើយ ថ្ងៃនេះមានមនុស្សជាច្រើននៅទីនេះបានដើរនៅ ក្នុងពន្លឺនៃបទគម្ពីរ ហើយនៅក្នុងការប្រកបគ្នានៃព្រះវិញ្ញាណបរិសុទ្ធជាមួយក្រុមជំនុំ។ ព្រះវិហារ ជាផលដំបូង ជាទារកទើបនឹងកើតដែលបានទទួលព្រះគ្រីស្ទ ហើយបានពេញដោយព្រះវិញ្ញាណបរិសុទ្ធ ដែលដឹកនាំដោយព្រះវិញ្ញាណ។ សូមឲ្យយើងដើរនៅក្នុងការប្រកបនេះរួមគ្នា នៅជុំវិញព្រះបន្ទូលរបស់ព្រះ បម្រើទ្រង់ នៅក្នុងពិធីបុណ្យជ្រមុជទឹក នៅក្នុងការគោរពចំពោះការសុគតរបស់ទ្រង់ និងការ រស់ឡើងវិញ។ សូមឲ្យយើងគោរពបទបញ្ជារបស់ទ្រង់ថា "ចូរចេញតាំងពីក្រុងយេរ៉ូសាឡឹមរហូតដល់ចុងបំផុត ដោយចេស្តារនៃឋានសួគ៌។" សូមឲ្យ យើងបម្រើទ្រង់នៅក្នុងការប្រោសឲ្យជារបស់ព្រះ។ អធិស្ឋានសម្រាប់អ្នកជំងឺ។ សូមឲ្យយើងបម្រើទ្រង់នៅក្នុងការរួមគ្នា ក្នុងការកាច់នំបុ័ង ដោយមានចិត្តនៃការ ប្រកបនៅជុំវិញព្រះបន្ទូលរបស់ព្រះ។ សូមឲ្យយើងបម្រើទ្រង់នៅក្នុងគ្រប់ទម្រង់ របស់ទ្រង់រហូតទាល់តែទឹកដីនោះបានមកដល់ជាក់ស្តែង។ សូមប្រទានមក ព្រះអង្គអើយ។ សូមស្តាប់សេចក្តីអធិស្ឋានរបស់យើង ដូចដែលយើងថ្វាយ ទាំងអស់ទៅទ្រង់ហើយ នៅក្នុងព្រះនាមនៃព្រះអម្ចាស់យេស៊ូវ។

144 ឥឡូវនេះសូមឱនក្បាលចុះដោយស្ងាត់ស្ងៀម យឺតៗ ហើយចូរច្រៀងបទចំរៀងនេះ។ ឥឡូវនេះគឺជាការថ្វាយបង្គំ។ សារបានបញ្ចប់។ គ្មាននរណាម្នាក់ចាកចេញទេ។ គ្រាន់តែសូមស្ងាត់។ ចូរថ្វាយបង្គំ។

145 ព្រះបន្ទូលគឺជាការកែតម្រូវ។ គិតឥឡូវនេះនូវអ្វីដែលអ្នកបានធ្វើ អ្វីដែលអ្នកគួរតែធ្វើ អ្វីដែលបណ្តាលឲ្យអ្នកមានថ្ងៃនេះ។ តើអ្វីធ្វើឲ្យអ្នកថ្កោលទោសនៅថ្ងៃនេះ ព្រោះអ្នកបានធ្វើអ្វីមួយកាលពីម្សិលមិញ។ តើថ្ងៃស្អែកនឹងទៅជាយ៉ាងណា? សូមធ្វើវាឲ្យបានត្រឹមត្រូវនៅថ្ងៃនេះ ហើយអ្នកនឹងមានសេរីភាពនៅថ្ងៃស្អែក។ ឃើញទេ? អ្នកត្រូវតែធ្វើការជ្រើសរើស។ តើអ្នកអាចធ្វើវាតាមរបៀបណា? "ដោយជំនឿខ្ញុំសូមប្រាប់បងប្អូនថា ខ្ញុំសុខចិត្តលះបង់ការអាក្រក់គ្រប់យ៉ាង។ ខ្ញុំលះបង់អស់ហើយឥឡូវ ថ្ងៃមួយខ្ញុំនឹងនៅទីនោះ។"

នៅក្នុងភាពផ្អែមល្ហែម
យើងនឹងជួបគ្នាលើឋានស្រស់...

គ្រាន់តែថ្វាយបង្គំព្រះដោយវិញ្ញាណអ្នកឥឡូវចុះ។

នៅក្នុងភាពផ្អែមល្ហែម
យើងនឹងជួបអ្នកដែលគេមើលងាយ។ (លំបាកនឹងទៅប៉ុន្តែ
យើងនឹងជួបថ្ងៃណាមួយ។)

ចំពោះព្រះវរបិតាដ៏ខ្ពង់ខ្ពស់របស់យើងខាងលើ
យើងនឹងថ្វាយការសរសើរតម្កើង
សម្រាប់អំណោយដ៏រុងរឿងនៃក្តីស្រឡាញ់ទ្រង់
ហើយពរជ័យដែលបន្សុទ្ធយើង...

ជាមួយព្រះដែលគេមើលងាយ ដោយសេចក្តីជំនឿខ្ញុំជ្រើសរើសទ្រង់។

នៅក្នុងភាពផ្អែមល្ហែម(ដោយភាពផ្អែម)ក្នុង...(ផ្អែមនិង
ផ្អែម)
យើងនឹងជួបនៅលើឆ្នេរស្រស់ស្អាតនោះ។(ផ្អែមនិងផ្អែម)
នៅក្នុងភាពផ្អែមល្ហែម (ផ្អែមល្ហែម) ដោយនិងដោយ
យើងនឹងជួបគ្នានៅឆ្នេរដ៏ស្រស់ស្អាតនោះ។

នោះគឺជាទឹកដីមួយ...

គ្រាន់តែថ្វាយបង្គំទ្រង់។ នេះគឺជាការថ្វាយបង្គំ។

...ដោយជំនឿខ្ញុំអាចមើលឃើញ

ដោយសេចក្តីជំនឿខ្ញុំជ្រើសរើស។

អូ! ព្រះវរបិតាសូមរង់ចាំ...

146 ខ្ញុំមើលឃើញព្រះអម្ចាស់នៅលើទីនោះ បងប្រុសជច បងប្រុសសេវេន (Seward) ពួកបរិសុទ្ធទាំងអស់។

...ពួកយើងជាទីលំនៅនៅទីនោះ។(ហ្នឹងហើយព្រះអង្គ
អើយ)
ផ្អែម...

147 ឪពុករបស់នាង លោកហាវើដ អេដវើដ អស់ទាំងមិត្តភក្តិដ៏ចំណាន់ដែលបាន ផ្លូវនោះ ជាយូរមកហើយ។

នៅក្នុងភាពផ្អែម (ហ្នឹងហើយព្រះអង្គអើយ!) ផ្អែមនិងផ្អែម (ផ្អែមនិងផ្អែម)
យើងនឹងជួបគ្នានៅឆ្នេរដ៏ស្រស់ស្អាតនោះ។

យើងនឹងច្រៀងនៅលើ...(អូ ព្រះអង្គអើយ!)
បទភ្លេងដែលច្រៀងចំរៀងសរសើរតម្កើង (ថ្វាយសិរីល្អដល់ព្រះ!)
...នឹងមិនមានទុក្ខព្រួយទៀតឡើយ
គ្មានសញ្ញាពរជ័យនៃទីកន្លែងដែលសំរាកនោះទេ។

នៅក្នុងភាពផ្អែមល្ហែម ផ្អែមដោយ...(ផ្អែមនិងផ្អែម)
យើងនឹងជួបគ្នានៅលើ...

**ដោយក្ដីជំនឿ លោកម៉ូសេ** KHM58-0720M

(By Faith, Moses)

សារដែលធ្វើឡើងដោយ William Marrion Branham នេះ ត្រូវបានចែកចាយនៅព្រឹក ថ្ងៃអាទិត្យ ថ្ងៃទី 20 កក្កដា 1958 នៅ រោងឧបោសថBranham Jeffersonville, Indiana, U.S.A។ រាល់ការខិតខំត្រូវបានធ្វើឡើងដោយការផ្ទៀងផ្ទាត់យ៉ាងត្រឹមត្រូវ ជាសារសម្លេងចេញពីខ្សែអាត់ថត ចម្លង និង បោះពុម្ពដោយរក្សាសិទ្ធពីភាសារអង់គ្លេស។ ការបក ប្រែជាភាសារខ្មែរនេះ គឺត្រូវបោះពុម្ព និង ចែកចាយដោយសម្លេងព្រះជាម្ចាស់ដែលបានថតទុក ។

KHMER

©2020 VGR, ALL RIGHTS RESERVED

VOICE OF GOD RECORDINGS
P.O. BOX 950, JEFFERSONVILLE, INDIANA 47131 U.S.A.
www.branham.org

# ការរក្សាសិទ្ធ

សៀវភៅនេះត្រូវបានរក្សាសិទ្ធ។ សៀវភៅនេះអាចថតចម្លង បានជាការប្រើប្រាស់ផ្ទាល់ខ្លួន ដោយសេរី ឥតគិតថ្លៃ ដើម្បីផ្សព្វផ្សាយដំណឹងល្អអំពីព្រះយេស៊ូគ្រិស្ត។ សៀវភៅនេះ មិនអាចលក់ ផលិតជាទ្រង់ទ្រាយធំ យកទៅដាក់ក្នុងវែបសាយ លក់តាមប្រព័ន្ធអេរលេចត្រូនីក ឬ បកប្រែ ដោយគ្មានការអនុញ្ញាតិពី វ៉យ អូហ្វ ហ្គត់ រីខខតឌីង (VOICE OF GOD RECORDINGS®.)ឡើយ។

សម្រាប់ទំនាក់ទំនងបន្ថែម និង ឬសម្រាប់តម្រូវការទាក់ទងនឹងឯកសារសូមទំនាក់ទំនង៖

វ៉យស៍ អូហ្វ ហ្គត់ រីខខតឌីង (VOICE OF GOD RECORDINGS)

P.O. BOX 950, JEFFERSONVILLE, INDIANA 47131 U.S.A.

WWW.BRANHAM.ORG